សាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា
CAMBODIAN UNIVERSITY FOR SPECIALTIES
Education for an Excellent Career

# អត្ថបទស្រាវជ្រាវ

## សេដ្ឋកិច្ច គណនេយ្យ គ្រប់គ្រង

## ស្តីពី

# គណនេយ្យអចលនទ្រព្យក្នុងការ
# គ្រប់គ្រងក្រុមហ៊ុនអាជីវកម្ម

## Research Working Paper

### Economics Accounting and Management

លេខ ០៥ ឆ្នាំទី ០៣
រក្សាសិទ្ធិ ២០២២

**និពន្ធនាយក៖** បណ្ឌិត មាស បូរ៉ា

**គណៈកម្មការត្រួតពិនិត្យខ្លឹមសារ៖**

-បណ្ឌិត កែវ ដា -បណ្ឌិត ម៉ាប៊ុនសែងឫទ្ធី - បណ្ឌិត សឿ យ៉ាន

-បណ្ឌិតឈេន ថន -បណ្ឌិត កៅ ដាណា -បណ្ឌិតកែវ សំអែល

**ក្រុមត្រួតពិនិត្យអក្ខរាវិរុទ្ធ និងរចនា៖**

-លោក មឿន វាសនា -លោក ឈន ថា - លោក ស៊ុន សារី

បោះពុម្ពលើកទី ០២ ចំនួន ១០០០ ក្បាល

រក្សាសិទ្ធិ ឆ្នាំ ២០២២

# អារម្ភកថា

អត្ថបទស្រាវជ្រាវនេះ ជាប្រភេទអត្ថបទសម្រាប់ធ្វើការសិក្សាស្រាវជ្រាវមួយផ្នែកសេដ្ឋកិច្ច គណនេយ្យ ពាណិជ្ជកម្ម ការគ្រប់គ្រង ដែលជាមុខវិជ្ជាសំខាន់ៗទាក់ទងយ៉ាងស៊ីជម្រៅទៅក្នុងការគ្រប់គ្រងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ ការងារធុរៈកិច្ចរបស់ក្រុមហ៊ុន និងស្ថាប័នសាធារណៈ ជាពិសេសពាក់ព័ន្ធជាមួយការគ្រប់គ្រងគណនេយ្យ-ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

ការគ្រប់គ្រងអចលនទ្រព្យរបស់ក្រុមហ៊ុន ឬក្រសួង-ស្ថាប័នទាំងអស់គឺជាការគ្រប់គ្រងទ្រព្យសម្បត្តិមានដូចជា អគារ រថយន្ត គ្រឿងម៉ាស៊ីនឧបករណ៍ គ្រឿងសង្ហារឹម។ល។ ដែល ក្រសួង-ស្ថាប័ន-ក្រុមហ៊ុនបានទិញរបស់បានបញ្ចេញប្រាក់ពីបេឡាធ្វើការចំណាយទិញទ្រព្យទាំងសម្រាប់កិច្ចប្រតិបត្តិការការងាររបស់គេ។បន្ទាប់មកត្រូវធ្វើការបែងចែកទ្រព្យសម្បត្តិទៅដល់បណ្ដាសាខាក្រោមចំណុះរាជធានី-ខេត្ត ឬសាខាក្រុមហ៊ុនដើម្បីដំណើរកិច្ចប្រតិបត្តិការការងារប្រចាំថ្ងៃ ខែ ត្រីមាស ឆមាស និងឆ្នាំ ក្នុងគោលបំណងប្រើប្រាស់ជាមធ្យោបាយផលិតកម្ម ក្នុងការគ្រប់គ្រង សាងសង់ ចំណាយផ្សេងៗ និងចំណាយមូលធនទៀតផង។ លើសពីនេះ អត្ថបទស្រាវជ្រាវនេះក៏បន្ថែមនូវការយល់ដឹងដូចជា ការរៀបចំថវិកាហិរញ្ញវត្ថុ ការអនុម័តថវិកាសម្រាប់ការទិញទ្រព្យសម្បត្តិចែកដល់បណ្ដាអង្គភាព និងសាខាក្រោមឱវាទសម្រាប់ប្រើប្រាស់។ការចំណាយនេះត្រូវការផ្ដល់សច្ចាប័នពីសភាជាតិឬក្រុមប្រឹក្សាភិបាលក្រុមហ៊ុនដើម្បីក្លាយជាគោលការណ៍/ច្បាប់ហិរញ្ញវត្ថុដែលបានទទួលស្គាល់ជាផ្លូវការចំពោះការគ្រប់គ្រងចំណូល-ចំណាយតាម

ក្រសួង-ស្ថាប័ន-ក្រុមហ៊ុន ប្រកបដោយការទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រង។

ទន្ទឹមនេះអត្ថបទនេះជាជំនួយមួយអំពីផ្នែកសេដ្ឋកិច្ច គណនេយ្យ ពាណិជ្ជកម្ម ការគ្រប់គ្រងនានាដែលសាស្ត្រាចារ្យឬនិស្សិតនៃសាកលវិទ្យាល័យខិតខំស្រាវជ្រាវ ដូចជា ដំណើរការគ្រប់គ្រងអចលនទ្រព្យ និងវិធីសាស្ត្រនៃការដករំលស់។ល។ វិធីសាស្ត្ររំលស់ត្រូវបានគេធ្វើឡើងដោយ វិធីសាស្ត្ររំលស់ថេរ វិធីសាស្ត្ររំលស់ថយជាលំដាប់ និងរំលស់តាមឯកតា។ ម្យ៉ាងវិញទៀត កន្លងមកសិស្ស និស្សិត បញ្ញវ័ន្ត និងអ្នកគ្រប់គ្រងអចលនទ្រព្យមួយចំនួន បានជួបនូវភាពលំបាកជាច្រើនដោយមានឯកសារពុំគ្រប់គ្រាន់សម្រាប់ស្រាវជ្រាវ ការពិគ្រោះ និងស្វែងយល់ ។ គួរតែចងចាំដែរថា កាលពីសម័យមុនប្រទេសកម្ពុជា ជាប្រទេសមួយមាន ក្បួនតម្រា ច្បាប់ គម្ពីដិកា សៀវភៅ គ្រប់ប្រភេទនៅមានដំកល់តាមបណ្ណាល័យ-វត្តអារ៉ាមនានាយ៉ាងសម្បូរណ៌បែបតែត្រូវបានបាត់បង់ខូចខាតអស់ជាច្រើនស្ទើរគ្មានសល់ក្នុងសម័យសង្គ្រាមវិនាសកម្មពីសម័យកាលមួយទៅសម័យកាលមួយតួយ៉ាងប៉ុន្មានទសវត្សចុងក្រោយនេះ។ មិនតែប៉ុណ្ណោះទៀតសោត សូម្បីអ្នកប្រាជ្ញ បណ្ឌិត កវី និពន្ធដែលមានសមត្ថភាពខ្ពង់ខ្ពស់ខាងចំណេះវិទ្យាសាស្ត្រ និងការតាក់តែងនិពន្ធក្តី ក៏បានស្លាប់អស់មួយចំនួនធំក្នុងពេលគ្រានោះដែរ។ ដោយមូលហេតុខាងលើនេះ ទើបជំរុញឲ្យក្រុមខ្ញុំបាទខិតខំស្រាវជ្រាវសរសេរចងក្រងជាអត្ថបទសិក្សាស្រាវជ្រាវនេះឡើងតាមកំរិតសមត្ថភាព និងបទពិសោធដែលខ្លួនមាន សម្រាប់ជាត្រីវិស័យមួយទុកផ្តល់ជូនដល់សិស្ស និស្សិត បញ្ញវ័ន្ត អ្នកគ្រប់គ្រងវិស័យសាធារណៈ អាជីវករ និងសាធារណៈជនមួយចំនួន ដើម្បីជាមូលដ្ឋានសម្រាប់ការស្រាវជ្រាវ ពិគ្រោះ និងស្វែងយល់

ព្រមទាំងចូលរួមចំណែកស្ថារ កសាង អភិវឌ្ឍន៍លើកស្ទួយសេដ្ឋកិច្ចជាតិ ផ្តល់ជាគំនិត ការយល់ដឹងអំពីការងារគ្រប់គ្រងអចលនទ្រព្យនិងហិរញ្ញវត្ថុដែលវិស័យជាអាទិភាពមួយក្នុងចំណោមវិស័យដ៏ទៃទៀត ក្នុងការស្វែងរកផលប្រយោជន៍ ជូនជាតិ-មាតុភូមិ និងប្រជាពលរដ្ឋកម្ពុជាឲ្យបានកាន់តែប្រសើរថែមទៀត ។

យើងខ្ញុំ មានការជឿជាក់យ៉ាងមុតមាំថា អត្ថបទស្រាវជ្រាវនេះ នឹងក្លាយជាឧបករណ៏គន្លឹះមួយ ជាពុទ្ធិមួយ ដែលអាចចូលរួមចំណែកជួយសម្រួល និងបង្កើនការយល់ដឹងពីតួនាទីភារកិច្ចដល់ថ្នាក់ដឹកនាំ អ្នកគ្រប់គ្រង និងបុគ្គលិកក្រោមឱវាទតាមក្រសួង-ស្ថាប័ន ថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រុមហ៊ុនក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការអចលនទ្រព្យនិងការអនុវត្តច្បាប់កាន់តែមានប្រសិទ្ធភាព។

ជាទីអវសាន ប្រសិនបើមាន ករណីទាំងឡាយណាដែលមានចំណុចពុំគួរ ខ្វះខាត យើងខ្ញុំរង់ចាំទទួលការរិះគន់ កែលម្អពីសំណាក់ប្រិយ៏មិត្ត អ្នកអានដោយសេចក្តីរីករាយ។

សូមជូនពរដល់ប្រិយមិត្តអ្នកអាន ជួបតែពុទ្ធពរទាំង៤ប្រការ គឺ អាយុៈ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ភ្នំពេញ ថ្ងៃទី ខែមេសា ឆ្នាំ ២០២២

**គណៈកម្មការនិពន្ធ**

# អត្ថបទស្រាវជ្រាវ ស្តីពី

# គណនេយ្យអចលនទ្រព្យក្នុងការគ្រប់គ្រងអាជីវកម្ម




## បណ្ឌិត កែវ ជា


## មាតិកា


I.សេចក្តីផ្តើម ........................................................................................ 3

ក-ការគ្រប់គ្រងទ្រព្យសកម្ម.............................................................................. 4

ខ-និយមន័យ .................................................................................................. 4

ខ-១-គណនេយ្យ ............................................................................................. 4

ខ-២-ទ្រព្យសកម្ម ................................Error! Bookmark not defined.

ខ-៣-សហគ្រាស.................................................................................................. 6

II. ការយល់ដឹងគណនេយ្យទ្រព្យសកម្មរបស់សហគ្រាស .......................... 8

a) រំលស់ និងលក្ខខណ្ឌរំលស់.................................................................... 8

b) ទ្រព្យសកម្មរយៈពេលវែងដែលអនុញ្ញាតឱ្យធ្វើរំលស់ ............................ 9

c) វិធីកត់ត្រាទ្រព្យសកម្មរយៈពេលវែង .......................................................12

D) រំលស់ត្រូវធ្វើនៅលើមូលដ្ឋាន និងក្នុងដែនកំណត់នៃថ្លៃដើម.................13

e) វិធីរំលស់ធម្មតា ..........................................................................................15

f) ពេលចាប់ផ្តើមធ្វើរំលស់ ...........................................................................17

g) រំលស់ត្រូវបានធ្វើយ៉ាងពិតប្រាកដដោយសហគ្រាស........................... 20

h) វិធីរំលស់ពិសេស ..................................................................................... 23

i) គោលការណ៍ ...... 26
j) ការគណនាតម្លៃលើសឬតម្លៃខ្វះ ...... 27
K) . ករណីពិសេស ...... 29
l) . ការកត់ត្រាតាមវដ្តគណនេយ្យ (ព្រឹត្តិការណ៍) ...... 30
m) ដំណោះស្រាយ ...... 32
n) សន្លឹកកិច្ចការ ...... 53
o) -ទិន្នានុប្បវត្តិបិទបញ្ជី ...... 54
p) .របាយការណ៍ហិញ្ញវត្ថុ ...... 55
**III.-សេចក្តីសន្និដ្ឋាន** ...... 58
**IV. ឯកសារយោង** ...... 59

## ខ្លឹមសារសង្ខេប

អនុលោមតាមការសិក្សាស្រាវជ្រាវអំពីគណនេយ្យអចលនទ្រព្យ គឺជាការវិនិយោគលើអចលនទ្រព្យដោយចំណាយលើការទិញ លើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ការពង្រីកផលិតកម្ម ដែលជាកត្តាចាំបាច់ត្រូវតែមានទ្រព្យសម្បត្តិសម្រាប់ដំណើរការកិច្ចប្រតិបត្តិការអាជីវកម្ម ហើយស្រប ជាមួយនោះដែរ ក្រុមហ៊ុនឬសហគ្រាសត្រូវក្នុងការរៀបចំឱ្យមានការគ្រប់គ្រងនូវទ្រព្យសកម្មរយៈពេលវែងបានល្អប្រសើរផងដែរ ក្រុមហ៊ុនត្រូវធ្វើការដករំលស់។ ការដករំលស់ គឺបង្ហាញអំពីការកត់ត្រា នៃការសឹករេចនៃទ្រព្យសកម្មដែលបណ្តាលមកពីការប្រើប្រាស់ ពេលវេលាប្រើប្រាស់ ការផ្លាស់ប្តូរបច្ចេកវិទ្យា ឬពីមូលហេតុផ្សេងទៀតដោយធ្វើការបែងរំលែកតម្លៃបរិយាទាននៃទ្រព្យសកម្មទៅតាមរយៈពេលគ្រោងទុកនៃការប្រើប្រាស់(អាយុកាលប្រើប្រាស់) អនុលោមទៅតាមផែនការរំលស់ប្រចាំឆ្នាំនីមួយៗ ដាក់បញ្ចូលក្នុងបន្ទុកនៃការចំណាយតាមឆ្នាំ។

ការដករំលស់នេះត្រូវធ្វើលើមូលដ្ឋាននៃថ្លៃដើមនៃទ្រព្យសកម្មដែលត្រូវដករំលស់ហើយត្រូវបូកយោងទឹកប្រាក់នៃការដករំលស់ទ្រព្យសកម្មណាមួយ ហើយមិនអាចដកលើសពីថ្លៃដើមទ្រព្យសកម្មនោះបានទេ។ទោះបីការវាយតម្លៃឡើងវិញធំជាងថ្លៃដើមក៏ដោយ។ ថ្លៃដើមអចលនទ្រព្យជាតម្លៃពីដំបូងនៃទ្រព្យសកម្មដែលមាន នៅពេលកំណត់ណាមួយ និងនៅទីកន្លែងណាមួយដែលទ្រព្យសកម្មនោះត្រូវបានកត់ត្រាក្នុងបញ្ជីគណនេយ្យបញ្ចូលទៅក្នុងទ្រព្យសម្បត្តិរបស់អង្គភាព។ ការចំណាយរំលស់ត្រូវបាន ដកចេញពី

តម្លៃប្រវត្តិសាស្ត្រនៃទ្រព្យកម្ម ដើម្បីបង្ហាញនូវតម្លៃបញ្ជីសុទ្ធសាធរបស់ទ្រព្យសកម្មតារាងតុល្យការ។ ទ្រព្យសកម្មនេះ មានទ្រព្យសកម្មរូបី និងអរូបីយ៍ ទ្រព្យសកម្មរូបីនេះត្រូវបានបែងចែកជា ៤ ថ្នាក់ ដូចខាងក្រោម៖

- ទ្រព្យថ្នាក់១៖ រួមមាន សំណង់នានា រួមបញ្ចូលទាំងអគារ រចនាសម្ព័ន្ធរបស់អគារ សំណង់ដែលជាសមាសភាគនៃអគារ ផ្លូវថ្នល់ ផ្លូវដែក នាវាដឹកជញ្ជូន
- ទ្រព្យថ្នាក់២៖ រួមមាន កុំព្យូទ័រ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឧបករណ៍អេឡិចត្រូនិច និងបរិក្ខារទុកដាក់ទិន្នន័យ
- ទ្រព្យថ្នាក់៣៖ រួមមាន រថយន្ត រថយន្តដឹកទំនិញ គ្រឿងសង្ហារឹម និងបរិក្ខារការិយាល័យ
- ទ្រព្យថ្នាក់៤៖ រួមមាន រាល់គ្រប់ប្រភេទនៃទ្រព្យសកម្មរូបីដទៃផ្សេងៗទៀត ក្រៅពីទ្រព្យក្នុងថ្នាក់១ ថ្នាក់២ និងថ្នាក់៣

ទ្រព្យសកម្មអរូបីយ៍នេះត្រូវបានបែងចែកជា ៤ ថ្នាក់ ដូចខាងក្រោម៖

# អត្ថបទស្រាវជ្រាវ ស្តីពី
# គណនេយ្យអចលនទ្រព្យក្នុងការគ្រប់គ្រងក្រុមហ៊ុនអាជីវកម្ម

## I. សេចក្តីផ្តើម

រាល់កិច្ចប្រតិបត្តិការអាជីវកម្ម ទោះបីនៅតាមរូបភាពណាក៏ដោយជាទូទៅ អចលនទ្រព្យដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការអាជីវកម្ម។ អចលនទ្រព្យ គឺជាទ្រព្យសកម្មមួយចំណែកធំ ក្រៅពីសាច់ប្រាក់ក្នុងបេឡា ឬ ធនាគារ និងទំនិញ វត្ថុធាតុដើម ស្តុកក្នុងឃ្លាំងសម្រាប់គាំទ្រក្នុងផ្នែកផលិតកម្ម និងទំនិញសម្រាប់លក់ ។ អចលនទ្រព្យក៏ជាទ្រព្យសម្បត្តិមួយផ្នែកដែលបំរើឲ្យការងារផលិតកម្មផ្ទាល់ និងបំពេញការងារផ្នែករដ្ឋបាល ក្នុងនោះ អ្នកជំនាញបច្ចេកទេស និងជំនាញគណនេយ្យ-ហិរញ្ញវត្ថុបានបែងចែកចំណាត់ថ្នាក់អចលនទ្រព្យជាមាន៤ ថ្នាក់ ចាប់ពីថ្នាក់ទ្រព្យថ្នាក់១ ដល់ថ្នាក់៤ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងទៅតាមថ្នាក់នីមួយៗ និងងាយស្រួលធ្វើការដករំលស់តាមបណ្តាឆ្នាំនីមួយ។ ការដករំលស់ទៅតាមឆ្នាំនីមួយៗ ជៀសវាងបញ្ចូលទៅថ្លៃដើមផលិតកម្មមានតម្លៃខ្ពស់ ដែលធ្វើឲ្យទំនិញមិនអាចប្រកួតប្រជែងនៅទីផ្សារបាន។

ការដករំលស់អចលនទ្រព្យនេះត្រូវកត់ត្រាបានច្បាស់លាស់អនុលោមស្របតាមគោលការណ៍គណនេយ្យដែលអាចទទួលស្គាល់ទូទៅ និងអនុលោមតាមស្តង់ដារគណនេយ្យកម្ពុជា និងស្តង់ដារគណនេយ្យអន្តរជាតិ ព្រមទាំងស្របតាមការកំណត់របស់រដ្ឋបាលសារពើពន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

តើការកត់ត្រាគណនេយ្យអចលនទ្រព្យក្នុងអាជីវកម្មយ៉ាងដូម្តេច ?

- តើការដករំលស់អចលនទ្រព្យបញ្ចូលទៅក្នុងរបាយការណ៍ចំណូលអនុលោមតាមស្តង់ដារគណនេយ្យកម្ពុជាដែរឬទេ ?

- តើការបង្ហាញអចលនទ្រព្យនៅក្នុងតារាងតុល្យការអនុលោមតាមស្តង់ដារគណនេយ្យកម្ពុជាដែរឬទេ?

ដើម្បីយល់ច្បាស់អ្នកសិក្សាស្រាវជ្រាវត្រូវយល់ច្បាស់អំពី និយមន័យដែលមានទំនាក់ទំនងជាមួយ គណនេយ្យ ទ្រព្យសកម្ម អចលនទ្រព្យ ការដកវំលស់ ។ល។ ដូចមានបង្ហាញដូចតទៅ៖

**ក-និយមន័យ**

**ក-១-គណនេយ្យ**

គណនេយ្យគឺជាដំណើរការនៃការកំណត់ ការវាស់វែង ការកត់ត្រា ការបញ្ជូននិងការបកស្រាយនូវប្រតិបត្តិការសេដ្ឋកិច្ចរបស់អង្គភាពមួយនៅក្នុងអំឡុងពេលមួយដ៏ជាក់លាក់។ រាល់ព័ត៌មានគណនេយ្យទាំងអស់(ប្រតិបត្តិការសេដ្ឋកិច្ច) ត្រូវពិពណ៌នាអំពីសាច់ប្រាក់។

**ក-២-ទ្រព្យសកម្ម**

ទ្រព្យសកម្ម គឺជាធនធានសេដ្ឋកិច្ច ដែលជាកម្មសិទ្ធិរបស់អង្គភាពអាជីវកម្មមួយ ហើយតាមរយៈទ្រព្យសកម្មនេះ គេរំពឹងថា នឹងទទួលបានចំណូលដោយឆ្លងតាមប្រតិបត្តិការរបស់អាជីវកម្ម។ ប្រភេទនៃទ្រព្យសកម្មត្រូវបានគេចែកជាពីរប្រភេទគឺ៖

១-ចលនទ្រព្យ ឬទ្រព្យសកម្មចរន្ត ( Current Assets) រួមមាន សាច់ប្រាក់ គណនីត្រូវទារ ស្តុកឃ្លាំងជាដើម

២- អចលនទ្រព្យ ឬទ្រព្យសកម្មរយៈពេលវែង( Fixed Assets)រួមមាន ដីធ្លី អគារ ផ្ទះសម្បែង គ្រឿងម៉ាស៊ីន រថយន្ត គ្រឿងសង្ហារឹម កុំព្យូទ័រ និងឧបករណ៍-បរិក្ខារជាដើម។ក្រុមហ៊ុនឬសហគ្រាសអាចចាត់ទុកអ្វីមួយជាទ្រព្យសកម្មបាន លុះត្រាតែទ្រព្យសកម្មនោះគោរពនូវលក្ខខណ្ឌបីយ៉ាង៖

- ជាកម្មសិទ្ធិ ឬសិទ្ធិត្រួតពិនិត្យរបស់អង្គភាព
- មានតម្លៃអាចគណនាបាន
- មានសារៈសំខាន់ចំពោះអង្គភាព។

ក្នុងការគ្រប់គ្រងទ្រព្យសកម្មគេបានបែងចែកជាទ្រព្យសកម្មរយៈពេលខ្លី និងទ្រព្យសកម្មរយៈពេលវែង។ នៅក្នុងក្រុមហ៊ុនឬសហគ្រាសនីមួយៗ តែងតែធ្វើការគ្រប់គ្រងទ្រព្យសកម្ម ដោយមានបញ្ជីទ្រព្យសកម្មរបស់ខ្លួន ហើយត្រូវធ្វើការគណនារំលស់សម្រាប់ទ្រព្យសកម្មរយៈពេលវែង ដោយស្របតាមការកំណត់របស់រដ្ឋបាលសារពើពន្ធតាមថ្នាក់នៃទ្រព្យនោះ។ ទ្រព្យសកម្មតែងត្រូវបានបង្ហាញ នៅក្នុងតារាងតុល្យការ នៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន/សហគ្រាស។

## ក-៣-អចលនទ្រព្យ

អចលនទ្រព្យគឺជាទ្រព្យដែលមិនអាចបំលាស់ទីបាន មានដូចជា ដី ផ្ទះ អាគារនិងសំណង់ផ្សេងៗដែលអាចប្រើប្រាស់ជាប្រយោជន៍បាន។ បើយើងប្រៀបធៀបតំលៃអចលនទ្រព្យពីពេលមុនរហូតមកដល់ពេលនេះគឺអចលនទ្រព្យកើនតំលៃជាដ៏រាបហើយមានចំនួនរាប់សិបដង រហូតដល់រយដង ដែលនេះបណ្តាលមកពីមូលហេតុចម្បងៗមួយចំនួនៈ-

- ចំនួនមានកំណត់
- ការកើនឡើងនៃចំនួនប្រជាពលរដ្ឋធ្វើអោយមានតម្រូវការប្រើប្រាស់ច្រើនជាងមុន
- អ្នកវិនិយោគមកពីក្រៅប្រទេស
- អតិផរណាកើនឡើងដោយសារអចលនទ្រព្យត្រូវបានប្តូរពីម្ចាស់មួយទៅមួយទៀត តំលៃចេះកើនឡើងរហូតដល់អ្នកប្រើប្រាស់ (ក្នុងពេលបច្ចុប្បន្នមានតំលៃខ្ពស់ជាងទីផ្សារពីទសវត្ស២០០០ ដោយចំនួនប្រជាពលរដ្ឋកើនឡើងតែជិតប្រាំដង មិនតែប៉ុណ្ណោះ

ពីជាងបីលាន មកជាងដប់ប្រាំមួយលាននាក់(ស្ថិតិជំរឿនទូទាំងប្រទេសឆ្នាំ២០១៩) ដែលនាំឲ្យអចលនទ្រព្យកើនឡើងរាប់រយដង ដូចជាប្រភេទអចលនវត្ថុមានដូចជា កសិកម្ម ឧស្សាហកម្ម លំនៅដ្ឋាន និងអាជីវកម្ម។

## ក-៣-សហគ្រាស

សហគ្រាស ឬអង្គភាពអាជីវកម្ម សំដៅដល់អង្គភាពដែលផ្តល់ទំនិញ និងសេវាកម្មដល់អតិថិជន។ សហគ្រាសធ្វើឡើងដើម្បីស្វែងរកប្រាក់ចំណេញ។ សហគ្រាសមានទម្រង់ដូចជា សហគ្រាសឯកកម្មសិទ្ធិ សហគ្រាសសហកម្មសិទ្ធិ និងសាជីវកម្ម។សហគ្រាសមានសហគ្រាសរបស់រដ្ឋ និងឯកជន។

មានអាជីវកម្មជាច្រើនប្រភេទនៅក្នុងសេដ្ឋកិច្ចទីផ្សារសេរី តែអ្នកសេដ្ឋវិទូបានបែងចែងសហគ្រាស ឬ ក្រុមហ៊ុន មាន ៣ ប្រភេទអាជីវកម្មសំខាន់ដូចតទៅ៖

១- ក្រុមហ៊ុនផលិតកម្ម
២- ក្រុមហ៊ុនលក់ទំនិញនិង
៣- សហគ្រាសសេវាកម្ម។

### ក-៣-១-ក្រុមហ៊ុនផលិតកម្ម

មានក្រុមហ៊ុនផលិតផលិតផលជាច្រើនដូចជា ក្រុមហ៊ុនផលិតធំ ៗ រួមមាន៖ក្រុមហ៊ុនផលិតយន្តហោះ រថយន្ត កុំព្យូទ័រ និងគ្រឿងសង្ហារឹម។ មានក្រុមហ៊ុនធំៗ បានប្រមូលផ្តុំផលិតផលសម្រាប់ទីផ្សារដែលអតិថិជនត្រូវការចាំបាច់ ។ឧទាហរណ៍៖ អ្នកផ្គត់ផ្គង់ឬផ្តល់នូវគ្រឿងបន្លាស់ឬបង្គុំ កុំព្យូទ័រ, រថយន្ត និងគ្រឿងប្រើប្រាស់ក្នុងផ្ទះ។ល។

### ក-៣-២-ក្រុមហ៊ុនលក់ទំនិញ

ក្រុមហ៊ុនលក់ទំនិញគឺជាអាជីវកម្មដែលជួយផ្លាស់ទីទំនិញតាមរយៈចែកចាយទំនិញដល់អតិថិជនចូលរួមក្នុងការលក់ដុំឬលក់រាយឬជួនកាលទាំងពីរ។

អ្នកលក់ដុំគឺជាអ្នកជំនួញដែលទិញទំនិញរួចហើយបនលក់ឱ្យអ្នកទិញជាធម្មតាឬលក់ឲ្យអ្នកលក់រាយបន្ត។

អ្នកលក់រាយគឺជាអ្នកជំនួញដែលលក់ទំនិញអោយអ្នកប្រើប្រាស់។

### ក-៣-៣-ក្រុមហ៊ុនសេវាកម្ម

សហគ្រាសសេវាកម្មរួមមានប្រភេទអាជីវកម្មជាច្រើន ឧទាហរណ៏៖ សហគ្រាសកាត់ដេរ ហាងជួសជុលស្បែកជើង អ្នកកាត់សក់ភោជនីយដ្ឋាន រមណីយដ្ឋានជិះស្គី មន្ទីរពេទ្យ និងសណ្ឋាគារ។ល។

### ក-៤- ទម្រង់នៃកម្មសិទ្ធិអាជីវកម្មនៃសហគ្រាស

មានទម្រង់ផ្សេងគ្នានៃភាពជាម្ចាស់អាជីវកម្ម។ ទាំងនេះរួមបញ្ចូលទាំង

ក- ឯកកម្មសិទ្ធិ

ខ- សហកម្មសិទ្ធិ ឬភាពជាដៃគូ,

គ- សាជីវកម្ម,

ឃ- ការបណ្ដាក់ទុនរួមគ្នា ឬ ក្រុមហ៊ុនចំរុះនិង

ង- សហជីព។

### ក-៤-១- សហគ្រាសនៃឯកកម្មសិទ្ធិ

- គឺជាកម្មសិទ្ធតែមួយគត់ដែលអាជីវកម្មមួយគ្រប់គ្រងដោយបុគ្គលម្នាក់។ នៅដើមសតវត្សរ៍ទី ២១ នេះមានច្រើនជាង ១៧ លានក្រុមហ៊ុននៅសហរដ្ឋអាមេរិក។

- ជាកម្មសិទ្ធិករក៏ជាម្ចាស់កម្មសិទ្ធិផងដែរ ហើយកម្មសិទ្ធិករទទួលខុសត្រូវដោយខ្លួនឯងចំពោះបំណុលអាជីវកម្មទាំងអស់ឬទទួលបានប្រាក់ចំណេញច្រើន។

## II. ការយល់ដឹងគណនេយ្យទ្រព្យសកម្មរបស់សហគ្រាស

ដើម្បីយល់ដឹងគណនេយ្យទ្រព្យសកម្មរបស់សហគ្រាសការទិញអចលនទ្រព្យតាមរយៈធ្វើលទ្ធកម្មដោយការទិញ ការទទួលបាន ការបញ្ចូលទ្រព្យសកម្ម

### a) រំលស់ និងលក្ខខណ្ឌរំលស់

រំលស់ និងលក្ខខណ្ឌរំលស់ ត្រូវបានកំណត់ដូចខាងក្រោម៖

១. លទ្ធកម្ម (ការទិញ ការទទួលបាន ការបញ្ចូល...) នៃទ្រព្យសកម្មរយៈពេលវែងពុំបណ្តាលឱ្យមានការថយចុះនៃទ្រព្យសកម្មទេ ពីព្រោះការចំណាយត្រូវបានជាថ្នូរបញ្ចូលមកវិញក្នុងទ្រព្យសកម្មរបស់សហគ្រាសនូវទ្រព្យសកម្មថ្មីមួយដែលពុំមានឥទ្ធិពលដល់លទ្ធផលជាប់ពន្ធឡើយ។ ទ្រព្យសកម្មរយៈពេលវែងតែងតែត្រូវសឹករេចដោយការប្រើប្រាស់និងដោយអាយុកាល ឬភាពហួសសម័យ ហើយការសឹករេចនេះ គឺជាចំណាយពិតប្រាកដមួយដែលត្រូវអនុញ្ញាតឱ្យកាត់កងពីប្រាក់ចំណូលជាប់ពន្ធរបស់សហគ្រាសតាមរយៈការធ្វើរំលស់។

២.រំលស់គឺជាការកត់ត្រាអំពីការសឹករេចនៃទ្រព្យសកម្មដែលបណ្តាល មកពីការប្រើប្រាស់ ពេលវេលាប្រើប្រាស់ ការផ្លាស់ប្តូរបច្ចេកវិទ្យា ឬពីមូលហេតុផ្សេងទៀតដោយធ្វើការបែងចែករំលែកបរិយាទាននៃទ្រព្យសកម្មទៅតាមរយៈពេលគ្រោងទុកនៃការប្រើប្រាស់ (អាយុកាលប្រើប្រាស់) ដែលផ្អែកតាមផែនការរំលស់មួយ។ រាល់ការកែប្រែធំដុំក្នុងលក្ខខណ្ឌនៃការប្រើប្រាស់ទ្រព្យសកម្មតម្រូវឱ្យមានការសើរើផែនការរំលស់ដែលកំពុងអនុវត្ត។

៣. សម្រាប់គោលដៅនៃពន្ធលើប្រាក់ចំណូល រំលស់ដែលអាចកាត់កងបានត្រូវបានបំពេញលក្ខខណ្ឌ ៥ ដូចខាងក្រោម៖

ក.រំលស់ត្រូវធ្វើតែលើទ្រព្យសកម្មរយៈពេលវែងដែលបានកត់ត្រាក្នុងទ្រព្យសកម្មនៃតារាងតុល្យការរបស់សហគ្រាស

ខ. រំលស់ត្រូវធ្វើតែលើទ្រព្យសកម្មរយៈពេលវែងដែលទទួលរងការសឹករេច

គ. រំលស់ត្រូវធ្វើលើមូលដ្ឋាន និងក្នុងដែនកំណត់នៃថ្លៃដើម

ឃ.រំលស់ត្រូវគណនាតាមវិធីដូចមានចែងក្នុងបទប្បញ្ញត្តិពន្ធដារជាធរមាន

ង. រំលស់ត្រូវបានធ្វើយ៉ាងពិតប្រាកដដោយសហគ្រាស។

ដោយឡែក ដីធ្លីមិនមែនជាទ្រព្យអាចរំលស់បានទេ។

៤. ក្នុងការកំណត់ប្រាក់ចំណូលជាប់ពន្ធ ការកាត់កងរំលស់តូវបានផ្តល់ឱ្យម្ចាស់ទ្រព្យសកម្មអរូបី ឬអ្នកជួលទ្រព្យសកម្មរូបីក្នុងករណីដែលអ្នកជួលទទួលខុសត្រូវលើហានិភ័យចំពោះការបាត់បង់ឬការខូចខាតនៃទ្រព្យ។ ជាធម្មតាចំពោះភតិសន្យាហិរញ្ញវត្ថុ ភតិកៈជាអ្នកទទួលរងនូវហានិភ័យខាងដើម។

## b ) ទ្រព្យសកម្មរយៈពេលវែងដែលអនុញ្ញាតឱ្យធ្វើរំលស់

១. សហគ្រាសធ្វើរំលស់តែលើទ្រព្យសកម្មរយៈពេលវែងដែលកត់ត្រាក្នុងទ្រព្យសកម្មនៃតារាងតុល្យការរបស់ខ្លួន។ ទ្រព្យសកមម្មរយៈពេលវែង គឺជាចំណែក (ឬសមាសភាគ) នៃទ្រព្យសកម្ម សម្រាប់ប្រើប្រាស់យូរអង្វែងនៅក្នុងសកម្មភាពអាជីវកម្ម និងរក្សាបាននូវរូបរាងដើមដដែលចាប់ពីពេលដាក់ប្រើប្រាស់រហូតដល់ពេលឈប់ប្រើការ។ អាចចាត់ទុកទ្រព្យសកម្មណាមួយជាទ្រព្យសកម្មរយៈពេលវែងប្រសិនបើទ្រព្យសកម្មនោះមានលក្ខណៈស្របតាមលក្ខណវិនិច្ឆ័យទាំងពីរដូចខាងក្រោម៖

ក. គោលដៅ៖ ទ្រព្យសកម្មគ្រប់ប្រភេទ (ទ្រព្យសកម្មអរូបី ឬទ្រព្យសកម្មរូបី) ដែលសហគ្រាសបានទិញឬបានផលិត មិនមែសម្រាប់បំប្លែងភាព

ដើម្បីលក់ ឬមិនមែនសម្រាប់លក់ ប៉ុន្តែសម្រាប់ប្រើប្រាស់យូរអង្វែង (ឧទាហរណ៍៖រថយន្តដែលសហគ្រាសទិញមកសម្រាប់លក់ទៅវិញ គឺជាចំណែកមួយនៃការទិញនិងស្តុក រីរថយន្តសម្រាប់ប្រើប្រាស់ក្នុងអាជីវកម្មរបស់សហគ្រាសគឺជាទ្រព្យសកម្មរយៈពេលវែង)។ ទ្រព្យសកម្មទាំងនេះអាចលក់ទៅវិញបានតែក្នុងករណីនៅក្រោយពេលបានប្រើប្រាស់រួចហើយ

ខ. រយៈពេល៖ ការរក្សាទុកទ្រព្យសកម្មនៅក្នុងអង្គភាពអាជីវកម្មត្រូវបានកំណត់ថា ជាប់លាប់ ប្រសិនបើមានរយៈពេលលើសពី ១ឆ្នាំ ដោយគិតចាប់ពីពេលដាក់ប្រើប្រាស់ដំបូង។

២.ភាពខុសគ្នារវាងទ្រព្យសកម្មរយៈពេលវែងនិងចំណាយ៖ ចំណាយដែលមានថ្លៃរជាការបញ្ចូលនូវចំណែកថ្មីមួយទៅក្នុងទ្រព្យសកម្មនៃសហគ្រាស គឺជាទ្រព្យសកម្មរយៈពេលវែង។ ចំពោះចំណាយទាក់ទិននឹងទ្រព្យសកម្មដែលបានកត់ត្រារួចហើយនៅក្នុងតារាងតុល្យការ។

៣. ទ្រព្យសកម្មរយៈពេលវែងត្រូវបានបែងចែកដូចខាងក្រោម៖

ក. ទ្រព្យសកម្មអរូបី៖

ទ្រព្យសកម្មអរូបីដែលអាចរំលស់បានជាអាទិ៍មាន៖

- ចំណាយបង្កើតសហគ្រាស
- ចំណាយស្រាវជ្រាវនិងអភិវឌ្ឍន៍៖គឺជាចំណាយនៃការស្រាវជ្រាវនិងអភិវឌ្ឍន៍ដែលសហគ្រាសបានធ្វើឡើងសម្រាប់បម្រើការងារអាជីវកម្ម។ ដូចគ្នានឹងចំណាយបង្កើតសហគ្រាសដែរ ចំណាយនេះគឺជាចំណាយគ្មានថ្លៃរមកវិញនៅក្នុងទ្រព្យសកម្មរបស់សហគ្រាសទេ។ គណនីទាំងឡាយដែលសម្រាប់កត់ត្រានូវចំណាយទាំងនេះ គឺជាគណនីទ្រព្យសកម្មដែលគ្មានតម្លៃពិតប្រាកដ។ ដូច្នេះក្នុងការកត់ត្រាជាទ្រព្យសកម្មរយៈពេលវែងនូវគម្រោង

ស្រាវជ្រាវនិងអភិវឌ្ឍន៍ណាមួយ គម្រោងការនេះត្រូវអាចសម្គាល់និងញែកដាច់តែឯងបាន និងត្រូវមានរំពឹងយ៉ាងមុខមាំក្នុងការទទួលផលខាងពាណិជ្ជកម្ម។

- ប្រកាសនីយបត្រ ពាណិជ្ជសញ្ញា អាជ្ញាប័ណ្ណ សម្បទាន កម្មវិធីកុំព្យូទ័រ (ចំណែកដែលមានច្បាប់ការពារ)
- មូលនិធិពាណិជ្ជកម្ម
- សិទ្ធិធ្វើអាជីវកម្ម
- ទ្រព្យសកម្មរយៈពេលវែងអរូបីផ្សេងទៀត

ទ្រព្យសកម្មអរូបីដែលមិនអាចរំលស់បាន ជាអាទិ៍មាន៖ មូលបត្រ ភាគកម្ម ទ្រព្យសកម្មរយៈពេលវែងហិរញ្ញវត្ថុផ្សេងៗ និងសិទ្ធិប្រើប្រាស់ដីធ្លី...។

ខ. ទ្រព្យសកម្មរូបី៖ ទ្រព្យកម្មរូបីត្រូវបានបែងចែកជា ៤ ថ្នាក់ ដូចខាងក្រោម៖

- ទ្រព្យថ្នាក់១៖ រួមមាន សំណង់នានា រួមបញ្ចូលទាំងអគារ រចនាសម្ព័ន្ធរបស់អគារ សំណង់ដែលជាសមាសភាគនៃអគារ ផ្លូវថ្នល់ ផ្លូវដែក នាវាដឹកជញ្ជូន
- ទ្រព្យថ្នាក់២៖ រួមមាន កុំព្យូទ័រ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឧបករណ៍អេឡិចត្រូនិច និងបរិក្ខារទុកដាក់ទិន្នន័យ
- ទ្រព្យថ្នាក់៣៖ រួមមាន រថយន្ត រថយន្តដឹកទំនិញ គ្រឿងសង្ហារឹម និងបរិក្ខារការិយាល័យ
- ទ្រព្យថ្នាក់៤៖ រួមមាន រាល់គ្រប់ប្រភេទនៃទ្រព្យសកម្មរូបីដទៃផ្សេងៗទៀត ក្រៅពីទ្រព្យក្នុងថ្នាក់១ ថ្នាក់២ និងថ្នាក់៣
- ក្នុងករណីទ្រព្យសកម្មរូបីណាមួយដែលមានលក្ខណៈពិសេស អគ្គនាយកដ្ឋានពន្ធដារអាចកំណត់វិធីរំលស់ដោយឡែកបាន។

## c) វិធីកត់ត្រាទ្រព្យសកម្មរយៈពេលវែង

១. ចំពោះទ្រព្យសកម្មអរូបី និងទ្រព្យសកម្មក្នុងថ្នាក់១ សហគ្រាសត្រូវកត់ត្រាដោយឡែកតាមគណនីទ្រព្យសកកម្មនីមួយៗ នូវទឹកប្រាក់ដែលជាប់ទាក់ទិននឹងទ្រព្យសកម្មនោះ (ថ្លៃទំនិញ ទឹកប្រាក់កាត់បន្ថយ ទឹកប្រាក់បង្វិលសងវិញ ការកែលម្អជាប់លាប់...។

២. ចំពោះទ្រព្យសកម្មរូបីក្នុងថ្នាក់២ ថ្នាក់៣ និងថ្នាក់៤ សហគ្រាសត្រូវកត់ត្រាក្នុងគណនីទ្រព្យសកម្មរួមសម្រាប់ថ្នាក់នីមួយៗ ហើយត្រូវកត់ត្រាចូលនូវចំនួនទឹកប្រាក់ដែលមិនទាន់ធ្វើរំលស់ ចំនួនទឹកប្រាក់ទាំងអស់ដែលទាក់ទិននឹងលទ្ធកម្មបន្ថែមនូវទ្រព្យសកម្ម (ការទិញបន្ថែម ការទទួលបន្ថែម ការបញ្ចូលបន្ថែម...) និងចំនួនទឹកប្រាក់ទាំងអស់ដែលទាក់ទិននឹងការបញ្ចេញទ្រព្យសកម្មក្នុងឆ្នាំជាប់ពន្ធ។

៣.ធនធានធម្មជាតិ៖ ចំណាយនានាក្នុងការស្វែងរុករកនិងអភិវឌ្ឍ រួមទាំងចំណាយការប្រាក់ទាក់ទិននឹងការស្វែងរុករកនិងអភិវឌ្ឍន៍ ត្រូវកត់ត្រាបង្គរទៅក្នុងគណនីធនធានធម្មជាតិ។

៤. កសិកម្មរយៈពេលវែង(ទ្រព្យសកម្មជីវសាស្ត្រ)

ក. ដំណាំសកម្ម៖ ត្រូវកត់ត្រាបង្គរទៅក្នុងគណនីទ្រព្យសកម្មជីវសាស្ត្រនូវចំណាយនានាក្នុងការអភិវឌ្ឍ ចំណាយពាក់ព័ន្ធផ្ទាល់ជាមួយការដាំដុះ រួមទាំងចំណាយការប្រាក់ទាក់ទិនទឹងការអភិវឌ្ឍនិងការដាំដុះ និងចំណាយរៀបចំហេដ្ឋារចនាសម្ព័ន្ធដែលបម្រើឱ្យការដាំដុះ

ខ. ការចិញ្ចឹមសត្វ៖ ត្រូវកត់ត្រាបង្គរទៅក្នុងគណនីទ្រព្យសកម្មជីវសាស្ត្រនូវចំណាយនានាក្នុងការអភិវឌ្ឍចំណាយពាក់ព័ន្ធផ្ទាល់ជាមួយការចិញ្ចឹមសត្វរួមទាំងចំណាយការប្រាក់ទាក់ទិននឹងការអភិវឌ្ឍនិងការចិញ្ចឹមសត្វនិងការចំណាយរៀបចំហេដ្ឋារចនាសម្ព័ន្ធដែលបម្រើឱ្យការចិញ្ចឹមសត្វ។

៥.ក្នុងករណីទ្រព្យសកម្មរយៈពេលវែងត្រូវបានប្រើប្រាស់កក្នុងអាជីវកម្មផងនិងប្រើប្រាស់ក្នុងការចិញ្ចឹមសត្វផង សហគ្រាសត្រូវអនុវត្តដូចខាងក្រោម៖

ក.ការប្រើប្រាស់ទ្រព្យសកម្មរយៈពេលវែងសម្រាប់ប្រើប្រាសតម្រូវការផ្ទាល់របស់ម្ចាស់សហគ្រាស ឬផ្តល់ឱ្យនិយោជិតឬតតិយជនត្រូវចាត់ទុកថាបានផ្តត់ផ្គង់សេវាតាមតម្លៃទីផ្សារ (កត់ត្រាចូលក្នុងចំណូលបន្ទាប់បន្សំ)។ ក្នុងករណីនេះការផ្តល់ឱ្យនិយោជិតត្រូវបានអនុញ្ញាតជាចំណាយកាត់កងបាននិងត្រូវជាប់ពន្ធលើអត្ថប្រយោជន៍បន្ថែម

ខ.ចំពោះសហគ្រាសឯកបុគ្គលឬសហគ្រាសសហកម្មសិទ្ធិ ការប្រើប្រាស់ដីនិងអគារផ្ទាល់ខ្លួនសម្រាប់ធ្វើអាជីវកម្មសហគ្រាសមិនត្រូវកត់ត្រាចូលក្នុងតារាងតុល្យការ ហើយក៏មិនត្រូវបានចាត់ទុកជាការជួសជុលដែរ។ ក្នុងករណីសហគ្រាសបានកត់ត្រាចូលក្នុងតារាងតុល្យការចំណាយរំលស់មិនត្រូវបានអនុញ្ញាតឱ្យកាត់កងពីប្រាក់ចំណូលជាប់ពន្ធឡើយ ហើយមិនត្រូវចាត់ទុកថាបានលក់ទេនៅពេលឈប់ប្រើប្រាស់ក្នុងអាជីវក-ម្ម។ ម្ចាស់ដីនិងអគារ រួមបញ្ចូលបុគ្គលទាំងឡាយដែលមានឈ្មោះក្នុងសៀវភៅគ្រួសារដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច

គ. ចំពោះសហគ្រាសដែលបានអនុវត្តតាមវិធានដូចជា ការប្រើប្រាស់ចម្រុះនូវទ្រព្យសកម្មរយៈពេលវែងកត់ត្រាក្នុងតារាងតុល្យការពុំមានផលប៉ះពាល់អ្វីដល់ការធ្វើរំលស់ទេ។

## d) រំលស់ត្រូវធ្វើនៅលើមូលដ្ឋាន និងក្នុងដែនកំណត់នៃថ្លៃដើម

១.រំលស់ត្រូវធ្វើលើមូលដ្ឋាននៃថ្លៃដើមនៃទ្រព្យសកម្មដែលត្រូវរំលស់។ ទឹកប្រាក់បូកយោងនៃរំលស់ទ្រព្យសកម្មណាមួយមិនអាចលើសពីថ្លៃទ្រព្យសកម្មនោះបានទេ ទោះបីការវាយតម្លៃឡើងវិញធំជាងថ្លៃដើមក៏ដោយ។ ថ្លៃដើមគឺជាតម្លៃពីដំបូងនៃទ្រព្យសកម្មនៅពេលណាមួយនិងនៅទីកន្លែង ដែលទ្រព្យសកម្មនោះត្រូវកត់ត្រាក្នុងបញ្ជីគណនេយ្យបញ្ចូលទៅក្នុងទ្រព្យរបស់សហគ្រាស។ ថ្លៃដើមនៃទ្រព្យសកម្មហៅថា បរិយាទានប្រវត្តិសាស្ត្រ ដែលជាគោលការណ៍មិនអាចកែប្រែបាន ឡើយ។

២.ថ្លៃដើមឬបរិយាទានប្រវត្តិសាស្ត្រនៃទ្រព្យសកម្មដែលត្រូវបញ្ចូលជាទ្រព្យសហគ្រាស ត្រូវបានកំណត់ដូចខាងក្រោម៖

ក.ចំពោះទ្រព្យសកម្មដែលសហគ្រាសបានទិញ ត្រូវកំណត់តាមថ្លៃទ្រព្យដែលបានទិញដោយៈ ត្រូវកត់ត្រាក្នុងបញ្ជីគណនេយ្យនូវថ្លៃទិញ ដកចេញនូវការបញ្ចុះថ្លៃ បូកបញ្ចូលនូវចំណាយបន្ទាប់បន្សំផ្សេងៗ (ពន្ធគយនិងចំណាយជាប់ទាក់ទិន ការដឹកជញ្ជូន ចំណាយឆ្លងកាត់និងឃ្លាំងស្តុក ចំណាយទទួលទ្រព្យសកម្មរយៈពេលវែង មានការលើកដាក់ ធានារ៉ាប់រងលើការដឹកជញ្ជូន...) និងចំណាយផ្គុំដំឡើងដែលចាំបាច់ក្នុងការដាក់ទ្រព្យសកម្មឱ្យដំណើរការ ចំណាយទូទៅ និងចំណាយហិរញ្ញវត្ថុទាក់ទិននឹងទ្រព្យសកម្មរយៈពេលវែង មិនត្រូវគិតបញ្ចូលក្នុងថ្លៃដើមនៃការទិញទេ ក្នុងករណីមានការពន្យាពេលទូទាត់ តម្លៃទ្រព្យសកម្មដែលត្រូវកត់ត្រា ត្រូវផ្អែកលើថ្លៃព្រមព្រៀង ដូច្នេះគឺពុំទាក់ទិនទៅនឹងបែបបទនៃការទូទាត់នៅថ្ងៃក្រោយឡើយ ទោះបីតម្លៃត្រូវសងកើនឡើងឬថយចុះក៏ដោយ

ខ. ចំពោះទ្រព្យសកម្មដែលសហគ្រាសបានផលិត ត្រូវកំណត់តាមថ្លៃដើមផលិតកម្មដោយៈត្រូវកត់ត្រាក្នុងបញ្ជីគណនេយ្យតាមតម្លៃពិតនៃផលិតកម្ម ដែលជាថ្លៃដើមនៃការទិញវត្ថុធាតុនិងសម្ភារផ្គត់ផ្គង់ដែលបានប្រើប្រាស់បូកបន្ថែមនូវចំណាយផ្ទាល់ទាំងអស់ (ចំណាយពលកម្ម ចំណាយសេវាខាងក្រៅ)និងចំណាយប្រយោលនៃផលិតកម្មក្នុងលក្ខណៈដែលចំណាយទាំងនោះអាចកំណត់បាននិងសមហេតុផលទៅក្នុងថ្លៃដើមផលិតកម្មនៃទ្រព្យសកម្មនោះ។ ថ្លៃដើមនៃផលិតកម្ម ត្រូវបានគណនាតាមគណនេយ្យថ្លៃដើម ឬប្រសិនបើគ្មានគណនេយ្យមថ្លៃដើមទេ ត្រូវគណនាតាមវិធីគណនាស្ថិតិថ្លៃដើមផលិតកម្មមិនត្រូវរួមបញ្ចូលទេនូវចំណាយលើការស្តុក ការលក់និងការគ្រប់គ្រងទូទៅ ការស្រាវជ្រាវនិង

អភិវឌ្ឍន៍ និងចំណាយហិរញ្ញវត្ថុ។ ដោយឡែកចំពោះថ្លៃដើមផលិតកម្ម នៃទ្រព្យសកម្មធំៗ ដូចជាការសាងសង់រោងចក្រឧស្សាហកម្ម ការដាំដំណាំឬការចិញ្ចឹមសត្វរយៈពេលវែង ការប្រាក់នៃបំណុលនានាដែលបានផ្តល់ទុនក្នុងការសាងសង់ ការដាំដុះឬការចិញ្ចឹមទាំងនេះ ត្រូវបានអនុញ្ញាតឱ្យបូកបញ្ចូលចាប់ពីពេលខ្ចីបុលដំបូងរហូតដល់ពេលធ្វើផលិតកម្មប៉ុណ្ណោះ

គ.ចំពោះទ្រព្យសកម្មដែលសហគ្រាសទទួលបានពីរដ្ឋ សមូហភាពសាធារណៈ ឬអ្នកវិនិយោគឯកជន ត្រូវកត់ត្រាក្នុងបញ្ជីគណនេយ្យតាមតម្លៃឧបហារិត ដូចដែលបានកំណត់ក្នុងកិច្ចព្រមព្រៀងនៃឧបហារិត

ឃ.ចំពោះទ្រព្យសកម្មដែលសហគ្រាសបានមកដោយគ្មានបង់ថ្លៃ ត្រូវកត់ត្រាក្នុងបញ្ជីគណនេយ្យតាមតម្លៃទីផ្សារ ឬថ្លៃដែលសហគ្រាសឯករាជ្យធ្វើប្រតិបត្តិការជាមួយគ្នា។

៣.អាករលើតម្លៃបន្ថែមដែលបានបង់លើការទិញឬផលិតទ្រព្យសកម្មដែលមិនអនុញ្ញាតជាឥណទានអាករលលើជាតុចូល ត្រូវបានអនុញ្ញាតឱ្យបូកបញ្ចូលក្នុងថ្លៃដើមនៃទ្រព្យនោះ។

## e) **វិធីរំលស់ធម្មតា**

វិធីរំលស់ធម្មតានៃទ្រព្យសកម្មរយៈពេលវែងត្រូវបានកំណត់ដូចខាងក្រោម៖

១. ទ្រព្យសកម្មអរូបី៖

ទ្រព្យសកម្មអរូបីទាំងអស់ត្រូវធ្វើរំលស់តាមវិធីរំលស់ស្មើភាគទៅតាមអាយុកាលប្រើប្រាស់នៃទ្រព្យទាំងនោះ ឬ ១០ ភាគរយក្នុងមួយឆ្នាំ ប្រសិនបើមិនអាចកំណត់អាយុកាលប្រើប្រាស់បាន។

២. ទ្រព្យសកម្មរូបី៖

- ទ្រព្យសកម្មថ្នាក់១៖ ត្រូវធ្វើរំលស់ដោយឡែកពីគ្នា តាមវិធីរំលស់ស្មើភាគតាមអត្រា ៥ ភាគរយ ក្នុងមួយឆ្នាំនៃបរិយាទានលទ្ធកម្ម (ថ្លៃដើម)។ ចំពោះអគារ ដែលមានលក្ខណៈជាអគារមិនមែនបេតុង រំលស់ត្រូវធ្វើឡើងតាមអត្រា ១០ ភាគរយ ក្នុងមួយឆ្នាំ
- ទ្រព្យសកម្មថ្នាក់២៖ ត្រូវធ្វើរំលស់តាមវិធីរំលស់ថយចុះជាលំដាប់តាមអត្រា ៥០ ភាគរយ នៃមូលដ្ឋានរំលស់ក្នុងមួយឆ្នាំ
- ទ្រព្យសកម្មថ្នាក់៣៖ ត្រូវធ្វើរំលស់តាមវិធីរំលស់ថយចុះជាលំដាប់តាមអត្រា ២៥ ភាគរយ នៃមូលដ្ឋានរំលស់ក្នុងមួយឆ្នាំ
- ទ្រព្យសកម្មថ្នាក់៤៖ ត្រូវធ្វើរំលស់តាមវិធីរំលស់ថយចុះជាលំដាប់តាមអត្រា ២០ ភាគរយ នៃមូលដ្ឋានរំលស់ក្នុងមួយឆ្នាំ

៣. ធនធានធម្មជាតិ៖ ទឹកប្រាក់រំលស់ដែលត្រូវបានអនុញ្ញាតឱ្យកាត់ក្នុងឆ្នាំជាប់ពន្ធណាមួយ ត្រូវបានគណនាដោយយកសមតុល្យនៃគណនីធនធានធម្មជាតិទៅគុណនឹងផលចែករវាងបរិមាណដែលផលិតបាននៅក្នុងឆ្នាំជាប់ពន្ធនិងចំនួនប៉ាន់ស្មាននៃផលិតផលសរុបដែលអាចទាញយកពីធនធាននោះ។

៤. កសិកម្មរយៈពេលវែង៖

ក. ដំណាំកៅស៊ូ៖ អនុញ្ញាតឱ្យធ្វើរំលស់ក្នុងរយៈពេល ២០ឆ្នាំ ទៅតាមអត្រាដែលបានកំណត់ដូចខាងក្រោម៖

| ឆ្នាំទទួលផល | អត្រារំលស់ |
| --- | --- |
| – ឆ្នាំទី១ និងទី២ | ៣% |
| – ឆ្នាំទី៣ និងទី៤ | ៤% |

| | |
|---|---|
| – ឆ្នាំទី៥ ដល់ឆ្នាំទី១០ | ៥% |
| – ឆ្នាំទី១០ និងទី១២ | ៧% |
| – ឆ្នាំទី១៣ ដល់ទី១៥ | ៦% |
| – ឆ្នាំទី១៦ ដល់ឆ្នាំទី១៩ | ៦% |
| – ឆ្នាំទី២០ | សមតុល្យនៅសល់ |

ខ. ដំណាំកសិកម្មក្រៅពីកៅស៊ូ៖ ទឹកប្រាក់រំលស់ដែលត្រូវបានអនុញ្ញាតឱ្យកាត់កងនៅក្នុងឆ្នាំជាប់ពន្ធណាមួយត្រូវគណនាតាមរំលស់ស្មើភាគតាមអាយុកាលនាំការទទួលផល ឬ ៥ ភាគរយក្នុងមួយឆ្នាំដោយជ្រើសរើសជម្រើសណាមួយដែលឆាប់ជាង

គ. ការចិញ្ចឹមសត្វ៖ ទឹកប្រាក់រំលស់ដែលត្រូវបានអនុញ្ញាតឱ្យកាត់កងនៅក្នុងឆ្នាំជាប់ពន្ធណាមួយត្រូវគណនាតាមវិធីរំលស់ស្មើភាគតាមអាយុកាលនៃការទទួលផល ឬ ១០ ភាគរយក្នុងមួយឆ្នាំដោយជ្រើសរើសជម្រើសណាមួយដែលឆាប់ជាង។

## f) ពេលចាប់ផ្តើមធ្វើរំលស់

១. រំលស់ទ្រព្យសកម្មតាមវិធីរំលស់ស្មើភាគត្រូវអនុវត្តដូចខាងក្រោម៖

ក. រំលស់ត្រូវធ្វើឡើងចាប់ពីពេលដែលទ្រព្យសកម្មត្រូវបានដាក់ប្រើប្រាស់ និងបញ្ចប់នៅពេលដែលទ្រព្យសកម្មត្រូវបានរំលស់អស់ (នៅពេលនោះទឹកប្រាក់រំលស់បូកយោងត្រូវស្មើនឹងថ្លៃដើមនៃទ្រព្យសកម្ម)។ ចំណុចបញ្ចប់ក៏អាចកើតមានឡើងមុនកាលបរិច្ឆេទរំលស់អស់ ដូចក្នុងករណីនៃការបញ្ចេញទ្រព្យសកម្មរបស់សហគ្រាសដោយការលក់ ការដាក់ទៅជាកាកសំណល់ឬបំផ្លាញចោលដែរ។ ទ្រព្យ

សកម្មដែលបានដាក់ឱ្យប្រើប្រាស់ក្នុងអំឡុងពេលណាមួយនៃឆ្នាំជាប់ពន្ធ ត្រូវអនុញ្ញាតឱ្យគិតរំលស់ពេញមួយឆ្នាំ

ខ. ចំពោះឆ្នាំបញ្ចប់រំលស់៖

- ក្នុងករណីទ្រព្យសកម្មត្រូវបានបញ្ចេញពីសហគ្រាស ទឹកប្រាក់រំលស់ត្រូវស្មើនឹងសូន្យ
- ក្នុងករណីទ្រព្យសកម្មណាមួយបានបញ្ចប់អាយុកាលប្រើប្រាស់របស់វា ទឹកប្រាក់រំលស់ត្រូវស្មើនឹងសមតុល្យមិនទាន់រំលស់នៃគណនីទ្រព្យសកម្មនៃទ្រព្យនោះ។ ប៉ុន្តែប្រសិនបើសមតុល្យនេះធំជាងទឹកប្រាក់រំលស់ប្រចាំឆ្នាំ (ឧទាហរណ៍៖ មានការកែលម្អជាប់លាប់) ទ្រព្យសកម្មជាប់លាប់ទាក់ទិនត្រូវបានចាត់ទុកថាវបានកើនអាយុកាលប្រើប្រាស់ និងត្រូវបានធ្វើរំលស់ជាបន្តទៀតរហូតដល់សមតុល្យនេះតូចជាងទឹកប្រាក់រំលស់ប្រចាំឆ្នាំ ទើបធ្វើរំលស់ឱ្យអស់ដើម្បីបញ្ចប់រំលស់តែម្តង។

២. រំលស់ទ្រព្យសកម្មតាមវិធីរំលស់ថយចុះជាលំដាប់ត្រូវអនុវត្តដូចខាងក្រោម៖

ក. រំលស់ត្រូវធ្វើឡើងចាប់ពីពេលដែលទ្រព្យសកម្មត្រូវបានដាក់ប្រើប្រាស់។ ទ្រព្យសកម្មដែលបានដាក់ប្រើប្រាស់ក្នុងអំឡុងពេលណាមួយនៃឆ្នាំជាប់ពន្ធ ត្រូវអនុញ្ញាតឱ្យគិតរំលស់ពេញមួយឆ្នាំ

ខ. ទឹកប្រាក់រំលស់ដែលអនុញ្ញាតឱ្យកាត់កងសម្រាប់ថ្នាក់នីមួយៗ ស្មើនឹងមូលដ្ឋានរំលស់គុណនឹងអត្រារំលស់សម្រាប់ថ្នាក់នីមួយៗ

គ. មូលដ្ឋានរំលស់សម្រាប់ឆ្នាំទី១ នៃអាជីវកម្ម គឺស្មើនឹងចំនួនសរុបនៃថ្លៃដើមនៃទ្រព្យសកម្មក្នុងគណនីទ្រព្យសកម្មរួមបញ្ចូលគ្នាតាមថ្នាក់នីមួយៗ

ឃ. ចំពោះឆ្នាំជាប់ពន្ធបន្តបន្ទាប់ មូលដ្ឋានរំលស់ស្មើនឹងសមតុល្យដើមគ្រានៃគណនីទ្រព្យសកម្មរួមបញ្ចូលគ្នាបូកនឹងថ្លៃដើមទ្រព្យសកម្មដាក់ប្រើប្រាស់ក្នុងឆ្នាំជាប់ពន្ធ ដកថ្លៃទ្រព្យសកម្មដែលបានដកចេញឬលក់ក្នុងឆ្នាំជាប់ពន្ធ

ង. នៅក្នុងឆ្នាំជាប់ពន្ធ ប្រសិនបើទ្រព្យណាមួយនៅក្នុងគណនីទ្រព្យសកម្មបញ្ចូលគ្នាត្រូវបានដកចេញឬលក់ពីអាជីវកម្ម សហគ្រាសត្រូវដកចេញពីមូលដ្ឋានរំលស់នៃទ្រព្យសកម្មរួមបញ្ចូលគ្នានូវតម្លៃទ្រព្យដែលបានដកចេញឬលក់នោះ។

- ប្រសិនបើការកត់ត្រាបែបនេះធ្វើឱ្យសមតុល្យគណនីទ្រព្យសកម្មរួមបញ្ចូលគ្នាក្លាយជាអវិជ្ជមាន សហគ្រាសត្រូវកត់ត្រាជាប្រាក់ចំណូលជាប់ពន្ធនូវប្រាក់ស្មើនឹងសមតុល្យអវិជ្ជមាននេះ ហើយសមតុល្យគណនីទ្រព្យសកម្មរួមបញ្ចូលគ្នាត្រូវកែតម្រូវមកសូន្យវិញ
- នៅចុងឆ្នាំជាប់ពន្ធ ប្រសិនបើក្នុងគណនីទ្រព្យសកម្មរួមបញ្ចូលគ្នាណាមួយ ជាក់ស្តែងគ្មាននៅសល់ទ្រព្យសកម្មអ្វីទៀតទេនោះ សមតុល្យវិជ្ជមាននៃទ្រព្យសកម្មរួមបញ្ចូលនោះ ត្រូវបានកត់ត្រាជាការខាតបង់អាចកាត់កងបាន ហើយសមតុល្យនៃគណនីទ្រព្យសកម្មរួមបញ្ចូលគ្នាត្រូវបានកែតម្រូវមកសូន្យវិញ។

៣. រំលស់ធនធានធម្មជាតិ ឬកសិកម្មរយៈពេលវែង៖ សហគ្រាសត្រូវចាប់ផ្តើមធ្វើរំលស់ធនធានធម្មជាតិ ឬ កសិកម្មរយៈពេលវែងនៅឆ្នាំដែលចាប់ផ្តើមធ្វើផលិតកម្ម។ ឆ្នាំចាប់ផ្តើមធ្វើផលិតកម្ម គឺជាឆ្នាំដែលសហគ្រាសបានទទួលពីការធ្វើអាជីវកម្មលើធនធានធម្មជាតិ ឬកសិកម្មរយៈពេលវែង។ ចំពោះទ្រព្យសកម្មរយៈពេលវែងដែលបានទិញឬបានបង្កើតក្រោយឆ្នាំចាប់ផ្តើមធ្វើផលិតកម្ម សហគ្រាសត្រូវធ្វើរំលស់នៅដំណាច់ឆ្នាំជាប់ពន្ធដែលទ្រព្យទាំងនោះត្រូវបានដាក់ឱ្យប្រើប្រាស់តាមវិធីសម្រាប់ធនធានធម្មជាតិ និងកសិកម្មរយៈពេលវែង។ ប្រសិនបើអាជីវកម្មលើធនធានធម្មជាតិ ឬកសិកម្មរយៈពេលវែង ត្រូវបានបញ្ចប់ក្នុងឆ្នាំជាប់ពន្ធណាមួយសហគ្រាសត្រូវបានអនុញ្ញាតឱ្យកាត់កងជាចំណាយនៅក្នុងឆ្នាំជាប់ពន្ធ នូវតម្លៃទ្រព្យសកម្មដែលនៅសេសសល់ទាំងអស់រួមបញ្ចូលទាំងចំណាយស្វែងរុករក ចំណាយអភិវឌ្ឍន៍ ចំណាយដាំដុះ និងចំណាយចិញ្ចឹមសត្វ។

### ខ) រំលស់ត្រូវបានធ្វើយ៉ាងពិតប្រាកដដោយសហគ្រាស

១. នៅក្នុងឆ្នាំជាប់ពន្ធនីមួយៗ សហគ្រាសត្រូវតែធ្វើរំលស់សម្រាប់ជានាការសើករេចដើម្បីកាត់កងក្នុងឆ្នាំជាប់ពន្ធនោះទោះបីមានប្រាក់ចំណូលជាប់ពន្ធគ្រប់គ្រាន់ ឬមិនគ្រប់គ្រាន់សម្រាប់ការកាត់កងក៏ដោយ។ រំលស់ត្រូវធ្វើយ៉ាងពិតប្រាកដដោយសហគ្រាសក្រោមមូលដ្ឋានបរិយាទានប្រវត្តិសាស្រ្ត។ ក្នុងករណីនៅដំណាច់ឆ្នាំជាប់ពន្ធណាមួយ សហគ្រាសធ្វើការវាយតម្លៃទៅតាមតម្លៃពិតបច្ចុប្បន្ននូវទ្រព្យសកម្មរបស់ខ្លួន (ធ្វើសារពើភណ្ឌលម្អិត) សហគ្រាសត្រូវជូនដំណឹងមករដ្ឋបាលសារពើពន្ធអំពីលទ្ធផលនៃការវាយតម្លៃនោះ។ សម្រាប់គោលដៅពន្ធដារ ប្រសិនបើលទ្ធផលនៃការវាយតម្លៃធ្វើឱ្យមានការប្រែប្រួលតម្លៃនៃទ្រព្យសកម្មក្នុងឆ្នាំជាប់ពន្ធ លម្អៀងលើសនៃការវាយតម្លៃឡើងវិញត្រូវចាត់ទុកជាប្រាក់ចំណូលជាប់ពន្ធ និងជាមូលដ្ឋានបន្ថែមសម្រាប់រំលស់បន្ត។

២. ទឹកប្រាក់រំលស់ដែលអាចកាត់កងបាន ត្រូវតែគណនាតាមបទប្បញ្ញត្តិពន្ធដារនិងបានកត់ត្រាក្នុងតារាងគណនារំលស់នៃលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំនៃឆ្នាំជាប់ពន្ធនីមួយៗ។

៣. សហគ្រាសមិនត្រូវបានអនុញ្ញាតឱ្យលើកពេលរំលស់ទ្រព្យសកម្មណាមួយទេ។

៤.ទឹកប្រាក់រំលស់ឬចំណែកណាមួយនៃទឹកប្រាក់រំលស់សម្រាប់ឆ្នាំជាប់ពន្ធណាមួយ ដែលពុំបានកត់ត្រាក្នុងតារាងគណនារំលស់នៃលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំមិនត្រូវបានអនុញ្ញាតឱ្យយកទៅកាត់កងក្នុងឆ្នាំជាប់ពន្ធផ្សេងទៀតបានឡើយ។

៥. រំលស់ដែលត្រូវបានបដិសេធចេញពីចំណាយអាចកាត់កងបាន ត្រូវបានចាត់ទុកថាត្រូវបានធ្វើឡើងជាប្រក្រតីសម្រាប់ការគណនាតម្លៃលើស ឬតម្លៃខ្វះនៃការលក់។

៦. ឧទាហរណ៍៖

ក. សហគ្រាសមួយបានទិញឃ្លាំងមួយនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៤ ដែលមានថ្លៃដើម ៤០០ ០០០ ០០០ រៀល។

ខ. សហគ្រាសបានធ្វើរំលស់ឃ្លាំងនោះជាទៀងទាត់តាមវិធីរំលស់ស្មើភាគ តាមអត្រា ៥ ភាគរយ សម្រាប់អាយុកាលប្រើប្រាស់ ២០ឆ្នាំ លើកលែងតែនៅឆ្នាំ ២០១៦ ដោយសារតែនៅឆ្នាំជាប់ពន្ធនោះ សហគ្រាសមានការខាតបង់ធ្ងន់ធ្ងរ

គ. ឃ្លាំងត្រូវបានលក់ចេញនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៨ បានប្រាក់ ១៥០ ០០០ រៀល

ឃ. ស្ថានភាពទាក់ទិននឹងការគណនារំលស់ តម្លៃលើសឬតម្លៃខ្វះ នៃ ឃ្លាំងនេះមានដូចតទៅ៖

- អត្រារំលស់៖ ៥ ភាគរយ (ឃ្លាំងមានអាយកាលប្រើប្រាស់ ២០ ឆ្នាំ ជាទ្រព្យសកម្មរូបីថ្នាក់១)
- រំលស់ត្រូវបានកត់ត្រាជាចំណាយសម្រាប់ឆ្នាំនីមួយៗ

– រំលស់ឆ្នាំ២០១៤ (៤០០ ០០០ ០០០ រៀល × ៥%) =
២០ ០០០ ០០០ រៀល (ឆ្នាំចាប់ផ្ដើមរំលស់គិតស្មើនឹងរំលស់ប្រចាំឆ្នាំ)

– រំលស់ឆ្នាំ២០១៥ = ២០ ០០០ ០០០ រៀល

– រំលស់ឆ្នាំ២០១៦ = ២០ ០០០ ០០០ រៀល

– រំលស់ឆ្នាំ២០១៧ = ២០ ០០០ ០០០ រៀល

– រំលស់ឆ្នាំ២០១៨ = ២០ ០០០ ០០០ រៀល

– រំលស់ឆ្នាំ២០១៩ = ២០ ០០០ ០០០ រៀល

– រំលស់ឆ្នាំ២០២០ = ២០ ០០០ ០០០ រៀល

– រំលស់ឆ្នាំ២០២១ = ២០ ០០០ ០០០ រៀល

– រំលស់ឆ្នាំ២០២២ = ២០ ០០០ ០០០ រៀល

– រំលស់ឆ្នាំ២០២៣ = ២០ ០០០ ០០០ រៀល

- រំលស់ឆ្នាំ២០២៤ = ២០ ០០០ ០០០ រៀល
- រំលស់ឆ្នាំ២០២៥ = ២០ ០០០ ០០០ រៀល
- រំលស់ឆ្នាំ២០២៦ = ២០ ០០០ ០០០ រៀល
- រំលស់ឆ្នាំ២០២៧ = ២០ ០០០ ០០០ រៀល
- រំលស់ឆ្នាំ២០២៨ = ០ រៀល (ឆ្នាំបញ្ចេញទ្រព្យសកម្មរំលស់គិតស្មើសូន្យ)
- តម្លៃនៅសល់មិនទាន់រំលស់ = ថ្លៃដើម (បរិយាទានប្រវត្តិសាស្ត្រ) – តម្លៃរំលស់បូកយោង
- ថ្លៃដើម (បរិយាទានប្រវត្តិសាស្ត្រ) = ៤០០ ០០០ ០០០ រៀល
- តម្លៃរំលស់បូកយោង = ២៦០ ០០០ ០០០ រៀល
- តម្លៃនៅសល់មិនទាន់រំលស់ = ១៤០ ០០០ ០០០ រៀល
- តម្លៃលើស = ថ្លៃលក់–តម្លៃនៅសល់មិនទាន់រំលស់
- ថ្លៃលក់ = ១៥០ ០០០ ០០០ រៀល
- តម្លៃនៅសល់មិនទាន់រំលស់ = ១៤០ ០០០ ០០០ រៀល
- តម្លៃលើស = ១០ ០០០ ០០០ រៀល

ង. សម្រាប់គោលដៅពន្ធដារ តម្លៃលើសនេះត្រូវតែបន្ថែមប្រាក់រំលស់លើកពេលចំនួន ២០ ០០០ ០០០ រៀល នៅឆ្នាំ២០១៦។ ដូច្នេះតម្លៃលើសជាប់ពន្ធ គឺ៣០ ០០០ ០០០រៀល(១០ ០០០ ០០០រៀល+ ២០ ០០០ ០០០ រៀល)

ច. ករណីនៃតម្លៃខ្វះ៖

ប្រសិនបើឃ្លាំងលក់បានថ្លៃ ១១០ ០០០ ០០០ រៀលវិញ តម្លៃខ្វះគឺ៖

- ថ្លៃលក់ = ១១០ ០០០ ០០០ រៀល
- តម្លៃនៅសល់មិនទាន់រំលស់ = ១៤០ ០០០ ០០០ រៀល
- តម្លៃខ្វះ (ខាត) = ៣០ ០០០ ០០០ រៀល

តម្លៃខ្វះ (ខាត) ដែលអាចកាត់កងបានសម្រាប់គោលដៅនៃពបច គឺមានតែ = ១០ ០០០ ០០០ រៀល ប៉ុណ្ណោះគឺតម្លៃដែលកត់ត្រាខាត ៣០ ០០០ ០០០ រៀល ត្រូវបានកាត់បន្ថយតម្លៃរំលស់លើកពេលក្នុងឆ្នាំ២០១៦ ចំនួន ២០ ០០០ ០០០ រៀល។

៧. ការកែតម្រូវលិខិតប្រកាសពន្ធលើប្រាក់ចំណូល៖

ក. ឆ្លងតាមឧទាហរណ៍ នេះ ឃើញថាសហគ្រាសត្រូវជាប់ពន្ធលើប្រាក់ចំណូល ចំពោះទឹកប្រាក់រំលស់ដែលបានលើកពេល។ សម្រាប់ការអនុវត្តជាក់ស្តែង សហគ្រាសត្រូវធ្វើការកែតម្រូវគណនីរំលស់ទ្រព្យសកម្មនៃឆ្នាំជាប់ពន្ធដែលមានកំហុស ដោយគិតបញ្ចូលមកវិញនូវទឹកប្រាក់រំលស់លើកពេល

ខ.ចំពោះទឹកប្រាក់រំលស់ឬទឹកប្រាក់សំវិធានធនដែលបង្កើតឡើងដោយខុសគោលការណ៍ ឬដែលមានទឹកប្រាក់លើសពីកម្រិតអនុញ្ញាត សហគ្រាសត្រូវកែតម្រូវទឹកប្រាក់រំលស់ឬសំវិធានធនដែលខុសនេះ សម្រាប់ឆ្នាំជាប់ពន្ធដែលមានកំហុស

គ.សម្រាប់ករណីដូចមានចែង សហគ្រាសត្រូវដាក់លិខិតប្រកាសកែតម្រូវប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ តាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធ

ឃ.នៅក្រោយពេលដែលសហគ្រាសបានអនុវត្តតាមបទប្បញ្ញត្តិ នេះរួចហើយ សហគ្រាសអាចធ្វើរំលស់ឬសំវិធានធនជាបន្តទៀតទៅតាមគោលការណ៍ដែលច្បាប់ស្តីពីសារពើពន្ធបានអនុញ្ញាត។

### h ) **វិធីរំលស់ពិសេស**

រំលស់ពិសេសត្រូវបានកំណត់ដូចខាងក្រោម៖

១.រំលស់ពិសេស ត្រូវបានអនុញ្ញាតឱ្យកាត់កងក្នុងឆ្នាំទី១ នៃការទិញ ឬនាពេលក្រោយមកទៀតនៅឆ្នាំទី១ នៃការដាក់ប្រើប្រាស់ទ្រព្យសកម្មរូបី។ ចំនួនដែលអនុញ្ញាតឱ្យកាត់កងនេះ ស្មើនឹង ៤០ ភាគរយ នៃតម្លៃមូលធននៃទ្រព្យសកម្មរូបីថ្មី ឬទ្រព្យសកម្មរូបីប្រើប្រាស់រួច ដែលបានដាក់ប្រើប្រាស់ក្នុងផលិតកម្មឬការកែច្នៃ។

ក្នុងឆ្នាំជាប់ពន្ធដដែល តម្លៃមូលធននៃទ្រព្យសកម្មរូបីដែលសល់ត្រូវបានអនុញ្ញាត ឱ្យធ្វើរំលស់តាមវិធីរំលស់ធម្មតា។

២. រំលស់ពិសេសនៃទ្រព្យសកម្មរូបី នឹងត្រូវបានយកមកកាត់កង ដើម្បីកំណត់ប្រាក់ចំណូលជាប់ពន្ធរបស់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រន់សម្រាប់ឆ្នាំជាប់ពន្ធ ប្រសិនអ្នកវិនិយោគមិនជ្រើសយកការប្រើប្រាស់សិទ្ធិទទួលរយៈពេលលើកលែងពន្ធដូចមានចែងក្នុងកថាខណ្ឌ៣ នៃមាត្រា ២០ ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធ។

៣.ទ្រព្យសកម្មរូបីដែលបានទទួលនូវការកាត់កងរំលស់ពិសេស ត្រូវដាក់ប្រើប្រាស់យ៉ាងតិចបំផុត ៤ ឆ្នាំជាប់ពន្ធបន្ទាប់ពីឆ្នាំជាប់ពន្ធដែលរំលស់ពិសេសត្រូវបានកាត់កង។ ប្រសិនបើទ្រព្យសកម្មរូបីនោះត្រូវបានឈប់ប្រើប្រាស់មុនរយៈពេលនេះ អ្នកវិនិយោគត្រូវកត់ត្រាបញ្ចូលក្នុងប្រាក់ចំណូលជាប់ពន្ធវិញចំនួនមួយស្មើនឹងទឹកប្រាក់រំលស់ពិសេសដែលបានកាត់កង កាត់បន្ថយដោយចំនួនបមួយស្មើនឹង ២ ភាគរយ នៃទឹកប្រាក់រំលស់ពិសេសដែលបានកាត់កងសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលទ្រព្យនោះត្រូវបានដាក់ប្រើប្រាស់។ ចំនួននេះនឹងមិនប៉ះពាល់ដល់តម្លៃពិតគណនេយ្យនៃទ្រព្យសកម្មរូបី សម្រាប់ការកំណត់ប្រាក់ចំណេញមូលធន តាមមាត្រា ៧ ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធទេ។

៤. ឧទាហរណ៍៖ សហគ្រាសវិនិយោគមួយចាប់ផ្តើមប្រកបអាជីវកម្មនៅដើមឆ្នាំជាប់ពន្ធ ២០១៤ មានម៉ាស៊ីន ៣ គ្រឿង សម្រាប់ប្រើប្រាស់ក្នុងអាជីវកម្ម។ សម្រាប់គោលដៅនៅនៃពន្ធលើប្រាក់ចំណូល ម៉ាស៊ីនស្ថិតក្នុងទ្រព្យសកម្មថ្នាក់៤ ដែលបានបានកត់ត្រាក្នុងតារាងរំលស់មានតម្លៃ ២៦ ០០០ ០០០ រៀល

- ម៉ាស៊ីនទី១៖ ១០ ០០០ ០០០ រៀល
- ម៉ាស៊ីនទី២៖ ១០ ០០០ ០០០ រៀល និង
- ម៉ាស៊ីនទី៣៖ ៦ ០០០ ០០០ រៀល។

នៅឆ្នាំ២០១៥ សហគ្រាសបានលក់ម៉ាស៊ីនទី៣ ទៅឱ្យសហគ្រាសផ្សេងក្នុងតម្លៃ ៥ ០០០ ០០០ រៀល ហើយបានទិញម៉ាស៊ីនគំរូថ្មីមួយគ្រឿងមកវិញមានតម្លៃ ២០ ០០០ ០០០ រៀល។

សហគ្រាសបានជ្រើសយកវិធីរំលស់ពិសេសសម្រាប់ដំណើរការវិនិយោគ។ រំលស់ត្រូវបានគណនាដូចខាងក្រោម៖

រំលស់ម៉ាស៊ីនទាំង ៣គ្រឿងសម្រាប់ឆ្នាំ២០១៤៖

- រំលស់ពិសេស(២៦ ០០០ ០០០×៤០%)=១០ ៤០០ ០០០ រៀល
- មូលដ្ឋានរំលស់ធម្មតា
  (២៦ ០០០ ០០០–១០ ៤០ ០០០)= ១៥ ៦០០ ០០០ រៀល
- រំលស់ធម្មតា(១៥ ៦០០ ០០០×២០%)=៣ ១២០ ០០០ រៀល
- សរុបរំលស់សម្រាប់ឆ្នាំ២០១៤
  (១០ ៤០០ ០០០+៣ ១២០ ០០០)=១៣ ៥២០ ០០០ រៀល
- មូលដ្ឋានរំលស់ដោយយោងទៅឆ្នាំ២០១៥
  (២៦ ០០០ ០០០– ១៣ ៥២០ ០០០) =១២ ៤៨០ ០០០ រៀល
  រំលស់សម្រាប់ឆ្នាំ២០១៥៖
- រំលស់ពិសេសសម្រាប់ម៉ាស៊ីនទិញថ្មី
  (២០ ០០០ ០០០×៤០%)= ៨ ០០០ ០០០ រៀល
- មូលដ្ឋានរំលស់ធម្មតាសម្រាប់ម៉ាស៊ីនទិញថ្មី
  (២០ ០០០ ០០០ –៨ ០០០ ០០០)=១២ ០០០ ០០០ រៀល
- មូលដ្ឋានរំលស់ធម្មតាសម្រាប់ម៉ាស៊ីនទាំងអស់៖
  ១២ ៤៨០ ០០០+ ១២ ០០០ ០០០– ៥ ០០០ ០០០ (ចំណូលពីការលក់ម៉ាស៊ីនចាស់) =១៩ ៤៨០ ០០០ រៀល
- ទឹកប្រាក់រំលស់ធម្មតា(១៩ ៤៨០ ០០០×២០%)=៣ ៨៩៦ ០០០រៀល
- សរុបទឹកប្រាក់រំលស់សម្រាប់ឆ្នាំ២០១៥

(៨ ០០០ ០០០+ ៣ ៨៩៦ ០០០)=១១ ៨៩៦ ០០០ រៀល

- មូលដ្ឋានរំលស់យោងទៅឆ្នាំ២០១៦

(១៩ ៤៨០ ០០០–១១ ៨៩៦ ០០០)=៧ ៥៨៤ ០០០ រៀល

ការកែតម្រូវពន្ធលើប្រាក់ចំណូលទាក់ទិននឹងការលក់ម៉ាស៊ីនក្នុងឆ្នាំ ២០១៥(បន្ទាប់ពីដាក់ប្រើបាន១៦ខែ)៖

- ប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ ២០១៥ ត្រូវបានកើនឡើងដោយសារការដែតម្រូវការកាត់កងរំលស់ពិសេសមកវិញនូវចំនួនទឹកប្រាក ២% សម្រាប់ខែនីមួយៗដែលទ្រព្យសកម្មបានដាក់ប្រើ។ ប្រាក់ចំណូលជាប់ពន្ធដែលត្រូវបញ្ចូលមកវិញសម្រាប់ឆ្នាំ២០១៥ ត្រូវបានគណនាដូចខាងក្រោម៖
  - រំលស់ពិសេស(៦ ០០០ ០០០×៤០%)=២ ៤០០ ០០០ រៀល
  - ដកចេញការកែតម្រូវសម្រាប់រយៈពេលដែលទ្រព្យសកម្មបានប្រើ (២ ៤០០ ០០០×២%)×១៦ខែ=៧៦៨ ០០០ រៀល
  - ប្រាក់ចំណូលជាប់ពន្ធដែលត្រូវបញ្ចូលមកវិញសម្រាប់ឆ្នាំ២០០៥ (២ ៤០០ ០០០–៧៨៦ ០០០ ០០០)=១ ៦៣២ ០០០ រៀល

តម្លៃលើសឬខ្វះដែលបានមកពីការលក់ម៉ាស៊ីន ត្រូវអនុវត្តតាមជំពូកទី៨ នៃប្រកាសនេះ។

## i) គោលការណ៍

១.អនុលោមតាមមាត្រា ៧ ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធ តម្លៃលើសដែលបានមកពីការលក់ចំណែកនានានៃទ្រព្យសកម្ម ក្នុងពេលកំពុងប្រកបអាជីកម្ម ឬនៅពេលបញ្ចប់អាជីវកម្មជាចំណែកមួយនៃប្រាក់ចំណូលជាប់ពន្ធ។

២. តម្លៃលើសឬតម្លៃខ្វះ កើតឡើងអំពីលម្អៀងរវាងថ្លៃលក់ និងតម្លៃនៅសល់មិនទាន់រំលស់នៃទ្រព្យសកម្ម ឬកើតឡើងអំពីការវាយតម្លៃឡើងវិញនូវទ្រព្យសកម្ម។

៣. តម្លៃលើសឬតម្លៃខ្វះ ត្រូវបានកំណត់ដូចខាងក្រោម៖

ក. តម្លៃលើសឬតម្លៃខ្វះដែលសម្រេចបាន៖ តម្លៃនេះកើតមានឡើងតាមការបញ្ចេញទ្រព្យសកម្មរយៈពេលវែងណាមួយ។ ការបញ្ចេញនេះអាចជាការលក់ (ករណីភាគច្រើន) ការធ្វើឧបហារិតទៅក្នុងសហគ្រាសមួយទៀត ការដោះដូរ ការបែងចែក ការផ្តល់អំណោយ ការយកវិញរបស់ម្ចាស់សហគ្រាសនាពេលកំពុងធ្វើអាជីវកម្មឬនាពេលបញ្ចប់អាជីវកម្ម ការរុះរើចេញ ការឈប់ប្រើប្រាស់...។ ការបញ្ចេញនេះអាចជាអំពើដោយចេតនារបស់ម្ចាស់សហគ្រាសឬអ្នកគ្រប់គ្រងសហគ្រាស ឬជាវិបាកនៃការដកហូតតាមផ្លូវច្បាប់ ឬគ្រោះមហន្តរាយ...

ខ. តម្លៃលើសបានកត់ត្រា៖ ការវាយតម្លៃឡើងវិញនូវទ្រព្យសកម្មដែលបានកត់ត្រាក្នុងបញ្ជីគណនេយ្យនូវតម្លៃបច្ចុប្បន្នរបស់ទ្រព្យទាំងនោះជំនួសឱ្យតម្លៃចាស់នាំឱ្យកើនឡើងនូវតម្លៃលើស។ តម្លៃលើសនេះជាតម្លៃគណនាសុទ្ធសាធ និងមិនមានឥទ្ធិពលលើប្រាក់ចំណូលជាប់ពន្ធឡើយ ក្នុងករណីដែលតម្លៃនេះមិនត្រូវបានប្រើប្រាស់ក្នុងគោលដៅរំលស់សារពើពន្ធ

គ. តម្លៃខ្វះក្រោមរូបភាពជាសំវិធានធនមិនត្រូវអនុញ្ញាតឱ្យកាត់កងជាចំណាយទេ វៀរលែងតែតម្លៃខ្វះដែលសម្រេចបាន។

## j) ការគណនាតម្លៃលើសឬតម្លៃខ្វះ

១. ការលក់ទ្រព្យសកម្មរយៈពេលវែងណាមួយបង្កើតបាននូវតម្លៃលើសកាលបើថ្លៃលក់មានតួលេខធំជាងតម្លៃនៅសល់មិនទាន់រំលស់នៃទ្រព្យសកម្មដែលបានលក់នោះ។

២. តម្លៃនៅសល់មិនទាន់រំលស់៖

ក. ចំពោះទ្រព្យសកម្មរយៈពេលវែងដែលត្រូវបានរំលស់តាមវិធីរំលស់ស្មើភាគ៖ តម្លៃនៅសល់មិនទាន់រំលស់ស្មើនឹងបរិយាទានប្រវត្តិសាស្ត្រនៃទ្រព្យសកម្មរយៈពេលវែងជាប់ទាក់ទិនណាមួយ បូកការកែលម្អជាប់លាប់ដកទឹកប្រាក់រំលស់បូកយោងដែលបានអនុវត្តចំពោះទ្រព្យនោះ

ខ. ចំពោះទ្រព្យសកម្មរយៈពេលវែងដែលត្រូវបានរំលស់តាមវិធីរំលស់ថយដាលំដាប់៖ ចំពោះការបញ្ចេញទ្រព្យសកម្មរយៈពេលវែងប្រភេទនេះណាមួយ សហគ្រាសមិនត្រូវគណនាតម្លៃលើស ឬតម្លៃខ្វះ សម្រាប់ទ្រព្យនោះដោយផ្ទាល់ទេ។ សហគ្រាសត្រូវអនុវត្តតាមបទប្បញ្ញត្តិ ហើយតម្លៃលើឬតម្លៃខ្វះនឹងត្រូវស្តែងចេញសម្រាប់គណនីទ្រព្យសកម្មរួមបញ្ចូលគ្នាក្នុងថ្នាក់នីមួយៗតែម្តង។

**៣. ឧទាហរណ៍៖**

ក. សហគ្រាសបានទិញនិងដាក់ឱ្យប្រើប្រាស់ទ្រព្យសកម្មថ្នាក់ទី១ ចំនួនមួយមានតម្លៃ ២៥០ ០០០ ០០០ រៀល។ នៅឆ្នាំទី៣ សហគ្រាសបានធ្វើការកែលម្អជាប់លាប់ចំនួន ៥០ ០០០ ០០០ រៀល នៅឆ្នាំទី៥ សហគ្រាសបានលក់ទ្រព្យសកម្មនោះចេញវិញក្នុងតម្លៃ ៣៥០ ០០០ ០០០ រៀល។

ខ. ការគណនារំលស់៖

- អត្រារំលស់៖ ៥ ភាគរយ (ទ្រព្យសកម្មរូបីថ្នាក់១)
- រំលស់ត្រូវបានកត់ត្រាជាចំណាយសម្រាប់ឆ្នាំនីមួយៗ៖
  - រំលស់ឆ្នាំទី១៖ ២៥០ ០០០ ០០០ ×៥%=១២ ៥០០ ០០០ រៀល
  - រំលស់ឆ្នាំទី២៖ ២៥០ ០០០ ០០០ ×៥%=១២ ៥០០ ០០០ រៀល
  - រំលស់ឆ្នាំទី៣៖ (២៥០ ០០០ ០០០+៥០ ០០០ ០០០)×៥%= ១៥ ០០០ ០០០ រៀល
  - រំលស់ឆ្នាំទី៤៖ (២៥០ ០០០ ០០០+៥០ ០០០ ០០០)×៥%= ១៥ ០០០ ០០០ រៀល
  - សរុបទឹកប្រាក់ដែលរំលស់យោង=៥៥ ០០០ ០០០ រៀល

គ. តម្លៃលើសឬតម្លៃខ្វះ៖

- បរិយាទានប្រវត្តិសាស្ត្រ =២៥០ ០០០ ០០០ រៀល
- ការកែលម្អជាប់លាប់ =៥០ ០០០ ០០០ រៀល
- រំលស់បូកយោង =៥៥ ០០០ ០០០ រៀល

- តម្លៃនៅសល់មិនទាន់រំលស់=២៤៥ ០០០ ០០០ រៀល
- ថ្លៃលក់ =៣៥០ ០០០ ០០០ រៀល
- តម្លៃលើស (៣៥០ ០០០ ០០០–២៤៥ ០០០ ០០០)= ១០៥ ០០០ ០០០ រៀល

k) . **ករណីពិសេស**

ករណីពិសេសមួយចំនួនទាក់ទិននឹងតម្លៃលើសឬខ្វះត្រូវបានកំណត់ដូចខាងក្រោម៖

១. ការខាតបង់ពីការលក់ ឬដោះដូរទ្រព្យសម្បត្តិ ទោះដោយផ្ទាល់ ឬប្រយោលក្តី រវាងបុគ្គលទាក់ទិនដែលមិនអនុវត្តតាមគោលការណ៍ជំហោងដៃ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃប្រកាសលេខ ៩៨៦ សហវ.ប្រកចុះថ្ងៃទី១០ ខែតុលា ឆ្នាំ ២០១៧ ស្តីពីវិធាននិងនីតិវិធីសម្រាប់បែងចែកចំណូលនិងចំណាយក្នុងចំណោមបុគ្គលទាក់ទិន។

២. ចំពោះឧបហារិតចូលក្រុមហ៊ុន តម្លៃលើសឬតម្លៃខ្វះត្រូវគណនាតាមតម្លៃពិតនៃសន្លឹកហ៊ុនដែលបានប្រគល់សម្រាប់ធ្វើជាថ្នូរនៃឧបហារិត។ ជាធម្មតាតម្លៃពិតនៃសន្លឹកហ៊ុន ត្រូវស្មើនឹងតម្លៃប៉ាន់ស្មាននៃទ្រព្យសកម្មដែលបានយកមកបញ្ចូលដោយឧបហារិតទៅក្នុងបញ្ជីគណនេយ្យរបស់សហគ្រាសដែលទទួលឧបហារិត។

៣. ចំពោះការដោះដូរ ទោះបីមានឬគ្មានការបន្ថែមប្រាក់ក៏ដោយ ត្រូវបានចាត់ទុកជាប្រតិបត្តិការលក់ និងប្រតិបត្តិការទិញជាធម្មតា។ តម្លៃលើសឬតម្លៃខ្វះ គឺស្មើនឹងទឹកប្រាក់លម្អៀងរវាងតម្លៃទីផ្សារនៃទ្រព្យកម្មដែលបានទទួលក្នុងការដោះដូរ និងតម្លៃនៅសល់មិនទាន់រំលស់នៃទ្រព្យសកម្មដែលបានដោះដូរគ្នា។ ការដោះដូរត្រូវជាប់ពន្ធក្នុងឆ្នាំជាប់ពន្ធដែលកើតមានការដោះដូរនេះ។

៤. ចំពោះការធ្វើអំណោយ ឬការដកយកវិញនូវទ្រព្យពីទ្រព្យសកម្មរបស់សហគ្រាស ឬការបញ្ឈប់សកម្មភាពអាជីវកម្ម តម្លៃលើសឬតម្លៃខ្វះនៃអំណោយ ឬទ្រព្យ ត្រូវគណនាតាមតម្លៃទីផ្សារនាថ្ងៃធ្វើអំណោយ ឬថ្ងៃដកយកវិញ ឬថ្ងៃបញ្ឈប់សកម្មភាព។

### 1) ការកត់ត្រាតាមវដ្តគណនេយ្យ (ព្រឹត្តិការណ៍)

ព្រឹត្តិការណ៍ ១. ក្រុមហ៊ុនអង្គរខន់ស្រ្កាក់សិន ត្រូវបានបង្កើតឡើងនៅថ្ងៃទី១ ខែមករា ឆ្នាំ២០២២ ដោយដាក់ដើមទុនរបស់ខ្លួនចំនួន ៩០០.០០០ ដុល្លារអាមេរិកជាសាច់ប្រាក់ និងអគារ១០០.០០០ដុល្លារអាមេរិក

ព្រឹត្តិការណ៍ ២. នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២២ ក្រុមហ៊ុនបានផ្តល់ សេវាកម្មសាងសង់តែ មិនទាន់បាន ទទួលសាច់ប្រាក់ ចំនួន២៨០.០០០ ដុល្លារអាមេរិក

ព្រឹត្តិការណ៍ ៣. នៅថ្ងៃទី ៨ ឧសភា ក្រុមហ៊ុនបានទទួលសាច់ប្រាក់ពីអតិថិជន ចំនួន ១៥០.០០០ ដុល្លារអាមេរិក

ព្រឹត្តិការណ៍ ៤. នៅថ្ងៃទី១៦ ខែមិថុនា ក្រុមហ៊ុនបានបើកប្រាក់ឈ្នួលឱ្យកម្មករ ចំនួន ៥០.០០០ ដុល្លារអាមេរិក

ព្រឹត្តិការណ៍ ៥. នៅថ្ងៃទី១ ខែកក្កដា ក្រុមហ៊ុនបានទិញរថយន្តមួយគ្រឿងតម្លៃ ១០.០០០ ដុល្លារអាមេរិក ទិញសង្ហារិម៨.០០០ ដុល្លារអាមេរិក និងទិញកុំព្យូទ័រ ៤.០០០ ដុល្លារអាមេរិក

ព្រឹត្តិការណ៍ ៦. នៅថ្ងៃទី១ ខែសីហាក្រុមហ៊ុនបានបង់មុនឱ្យក្រុមហ៊ុនផ្សាយពាណិជ្ជកម្មចំនួន៣.០០០ ដុល្លារអាមេរិក

ព្រឹត្តិការណ៍៧. នៅថ្ងៃទី១០ ខែកញ្ញា ក្រុមហ៊ុនបានទទួលការសាងសង់មួយដែលមានតម្លៃ ១៦០.០០០ដុល្លារអាមេរិក

ព្រឹត្តិការណ៍ ៨. នៅថ្ងៃទី១៥ ខែកញ្ញា ក្រុមហ៊ុនបានទទួលសាច់ប្រាក់ចំនួន
១៣០.០០០ ដុល្លារទៀត

ព្រឹត្តិការណ៍ ៩. នៅថ្ងៃទី៣០ ខែធ្នូ ក្រុមហ៊ុនបានបើកប្រាក់ឈ្នួលឱ្យកម្មករ ចំនួន
៥០.០០០ ដុល្លារអាមេរិក

ព្រឹត្តិការណ៍ ១០. នៅថ្ងៃទី៣១ ខែធ្នូ ក្រុមហ៊ុនបានបង់ថ្លៃទឹកភ្លើងចំនួន៥.០០០
ដុល្លារអាមេរិក។

ការណែនាំ៖

ចូររៀបចំដោយសង្ខេបរបស់ប្រតិបត្តិគណនេយ្យអាជីវកម្មខាងលើក្នុងខែធ្នូ តាមការកំណត់ ដូចខាងក្រោម÷

**<u>ករណី(ក)</u>**

១-កិច្ចបញ្ជីកា(Transaction)

២-មូលដ្ឋានវិភាគ(Basic Analysis)

៣-វិភាគសមីការគណនេយ្យ(Accounting Equation Analysis)

៤-វិភាគឥណពន្ធ-ឥណទាន(Debit-Credit Analysis)

៥-ការចុះទិន្នានុប្បវត្តិ(Journal Entry)

៦-ការចុះសក្ខីបត្រចុះបញ្ជី(Posting Entry)

**<u>ករណី(ខ)</u>**

១-ការកត់ត្រាសមីការគណនេយ្យសង្ខេប(Equation Account Summary)

២-ការកត់ត្រាទិន្នានុប្បវត្តិទូទៅ(General Journal)

៣-ការកត់ត្រាសៀវភៅធំទូទៅ(General ledger)

៤-បង្កើតរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន (CREATE THE FINANCIAL STATEMENT OF COMPANY'S)។

## ៣) ដំណោះស្រាយ

<u>ករណី(ក)</u>

ព្រឹត្តិការណ៍ ១.

ក្រុមហ៊ុនអង្គរខន់ស្ត្រាក់សិន ត្រូវបានបង្កើតឡើងនៅថ្ងៃទី១ ខែមករា ឆ្នាំ ២០២២ ដោយដាក់ដើមទុនរបស់ខ្លួនចំនួន ៩០០.០០០ ដុល្លារអាមេរិកជាសាច់ប្រាក់ និងអគារ១០០.០០០ដុល្លារអាមេរិកមូលដ្ឋាននៃការវិភាគ សាច់ប្រាក់កើនឡើងចំនួន $៩០០.០០០ ទ្រព្យសកម្មកើនឡើងចំនួន $១០០.០០០ មូលធនទ្រព្យម្ចាស់កើនឡើងចំនួន$ ១.០០០.០០០។

### ការវិភាគសមីការគណនេយ្យ

| ទ្រព្យសកម្ម | | | | = | បំណុល | + | មូលធនទ្រព្យម្ចាស់ |
|---|---|---|---|---|---|---|---|
| សាច់ប្រាក់ | គណនីត្រូវទារ | អគារ | បរិក្ខារ | | គណនីត្រូវសង | | ដើមទុនលោកបូរី |
| +៩០០.០០០ | | +១០០.០០០ | | | | | +១.០០០.០០០ |

### ការវិភាគឥណពន្ធ-ឥណទាន

សាច់ប្រាក់

| ឥណពន្ធ | ឥណទាន |
|---|---|
| $ ៩០០.០០០ | |

អគារ

| ឥណពន្ធ | ឥណទាន |
|---|---|
| $ ១០០.០០០ | |

មូលធនទ្រព្យម្ចាស់

| ឥណពន្ធ | ឥណទាន |
|---|---|
| | $ ១.០០០.០០០ |

ការចុះទិន្នានុប្បវត្តិ

| ថ្ងៃខែឆ្នាំ | បរិយាយ | គណនី | | |
|---|---|---|---|---|
| ១ មករា | សាច់ប្រាក់ | ១០១ | $ ៩០០.០០០ | |
| | អគារ | ១០៣ | $ ១០០.០០០ | |
| | មូលធនទ្រព្យម្ចាស់ (ដើមទុនបង្កើតក្រុមហ៊ុន) | ៣០១ | | $ ១.០០០.០០០ |

**ការចុះសក្ខីបត្រចុះបញ្ជី**

| សាច់ប្រាក់ | ១០១ |
|---|---|
| ១ មករា $ ៩០០.០០០ | |

| អគារ | ១០៣ |
|---|---|
| ១ មករា $ ១០០.០០០ | |

| មូលធនទ្រព្យម្ចាស់ | ៣០១ |
|---|---|
| | ១ មករា $ ១.០០០.០០០ |

ព្រឹត្តិការណ៍ ២.

នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២២ ក្រុមហ៊ុនបានផ្តល់ សេវាកម្មសាងសង់តែមិនទាន់បាន ទទួលសាច់ប្រាក់ ចំនួន២៨០.០០០ ដុល្លារអាមេរិក

មូលដ្ឋាននៃការវិភាគគណនីត្រូវទារកើនឡើងចំនួន $ ២៨០.០០០

ចំណូលកើនឡើងចំនួន $២៨០.០០០

## ការវិភាគសមីការគណនេយ្យ

| ទ្រព្យសកម្ម | | | | = | បំណុល | + | មូលធនទ្រព្យម្ចាស់ |
|---|---|---|---|---|---|---|---|
| សាច់ប្រាក់ | គណនីត្រូវទារ | អគារ | បរិក្ខារ | | គណនីត្រូវសង | | ដើមទុនលោកបូរី |
| +៩០០.០០០ | | +១០០.០០០ | | | | | +១.០០០.០០០ |
| | +២៨០.០០០ | | | | | | +២៨០.០០០ |

## ការវិភាគឥណពន្ធ-ឥណទាន

គណនីត្រូវទារ

| ឥណពន្ធ | ឥណទាន |
|---|---|
| $ ២៨០.០០០ | |

ចំណូល

| ឥណពន្ធ | ឥណទាន |
|---|---|
| | $ ២៨០.០០០ |

ការចុះទិន្នានុប្បវត្តិ

| | | | | |
|---|---|---|---|---|
| ១៩ | គណនីត្រូវទារ | ១០២ | $ ២៨០.០០០ | |
| កុម្ភៈ | ចំណូល | ៤០១ | | $ ២៨០.០០០ |
| | (ចំណូលពីសេវាសាងសង់) | | | |

## ការចុះសក្ខីបត្រចុះបញ្ជី

គណនីត្រូវទារ ១០២

| | |
|---|---|
| ១៩ កុម្ភៈ $ ២៨០.០០០ | |

គណនីត្រូវទារ ៤០១

| | |
|---|---|
| | ១៩ កុម្ភៈ $ ២៨០.០០០ |

ព្រឹត្តិការណ៍ ៣. នៅថ្ងៃទី ៨ ឧសភា ក្រុមហ៊ុនបានទទួលសាច់ប្រាក់ពីអតិថិជន ចំនួន ១៥០.០០០ ដុល្លារអាមេរិក

មូលដ្ឋាននៃការវិភាគ សាច់ប្រាក់កើនឡើង ចំនួន $ ១៥០.០០០ ហើយ គណនីត្រូវទារថយចុះ ចំនួន $ ១៥០.០០០

ការវិភាគសមីការគណនេយ្យ

**ទ្រព្យសកម្ម = បំណុល + មូលធនទ្រព្យម្ចាស់**

| សាច់ប្រាក់ | គណនីត្រូវទារ | អគារ | បរិក្ខារ | | គណនីត្រូវសង | | ដើមទុនលោកបូរី |
|---|---|---|---|---|---|---|---|
| +៩០០.០០០ | | +១០០.០០០ | | | | | +១.០០០.០០០ |
| | +២៨០.០០០ | | | | | | +២៨០.០០០ |
| +១៥០.០០០ | - ១៥០០.០០០ | | | | | | |

**ការវិភាគឥណពន្ធ-ឥណទាន**

សាច់ប្រាក់

| ឥណពន្ធ | ឥណទាន |
|---|---|
| $ ១៥០.០០០ | |

គណនីត្រូវទារ

| ឥណពន្ធ | ឥណទាន |
|---|---|
| | $ ១៥០.០០០ |

ការចុះទិន្នានុប្បវត្តិ

| | | | | |
|---|---|---|---|---|
| ៨ ឧសភា | សាច់ប្រាក់ | ១០១ | $ ១៥០.០០០ | |
| | គណនីត្រូវទារ (អតិថិជនសងប្រាក់) | ១០២ | | $ ១៥០.០០០ |

## ការចុះសក្ខីបត្រចុះបញ្ជី

| សាច់ប្រាក់ ១០១ | |
|---|---|
| ៨ ឧសភា | |
| $ ១៥០.០០០ | |

| គណនីត្រូវទារ ១០២ | |
|---|---|
| | ៨ ឧសភា |
| | $ ១៥០.០០០ |

ព្រឹត្តិការណ៍ ៤.

នៅថ្ងៃទី១៦ ខែមិថុនា ក្រុមហ៊ុនបានបើកប្រាក់ឈ្នួលឱ្យកម្មករ ចំនួន ៥០.០០០ ដុល្លារអាមេរិកមូលដ្ឋាននៃការវិភាគ ចំណាយកើនឡើងចំនួន $ ៥០.០០០ សាច់ប្រាក់ថយចុះចំនួន $ ៥០.០០០

## ការវិភាគសមីការគណនេយ្យ

| ទ្រព្យសកម្ម | | | | = | បំណុល | + | មូលធនទ្រព្យម្ចាស់ |
|---|---|---|---|---|---|---|---|
| សាច់ប្រាក់ | គណនីត្រូវទារ | អគារ | បរិក្ខារ | | គណនីត្រូវសង | | ដើមទុនលោកបូរី |
| +៩០០.០០០ | | +១០០.០០០ | | | | | +១.០០០.០០០ |
| | +២៨០.០០០ | | | | | | +២៨០.០០០ |
| +១៥០.០០០ | - ១៥០.០០០ | | | | | | |
| -៥០.០០០ | | | | | | | -៥០.០០០ |

**ការវិភាគឥណពន្ធ-ឥណទាន**

| សាច់ប្រាក់ | |
|---|---|
| ឥណពន្ធ | ឥណទាន |
| $ ៥០.០០០ | |

| ចំណាយប្រាក់ឈ្នួល | |
|---|---|
| ឥណពន្ធ | ឥណទាន |
| | $ ៥០.០០០ |

ការចុះទិន្នានុប្បវត្តិ

| ថ្ងៃខែឆ្នាំ | បរិយាយ | គណនី | ឥណពន្ធ | ឥណទាន |
|---|---|---|---|---|
| ១៦ | ចំណាយប្រាក់ឈ្នួល | ៥០១ | $ ៥០.០០០ | |
| មិថុនា | សាច់ប្រាក់ | ១០១ | | $ ៥០.០០០ |
| | (បើកប្រាក់ឈ្នួលឱ្យកម្មករ) | | | |

**ការចុះសក្ខីបត្រចុះបញ្ជី**

| ចំណាយប្រាក់ឈ្នួល ៥០១ | |
|---|---|
| ១៦ មិថុនា $ ៥០.០០០ | |

| សាច់ប្រាក់ ១០១ | |
|---|---|
| | ១៦ មិថុវា $ ៥០.០០០ |

ព្រឹត្តិការណ៍ ៥. នៅថ្ងៃទី១ ខែកក្កដា ក្រុមហ៊ុនបានទិញរថយន្តមួយគ្រឿងតម្លៃ ១០.០០០ ដុល្លារអាមេរិក ទិញសង្ហារិម៨.០០០ ដុល្លារអាមេរិក និងទិញកុំព្យូទ័រ ៤.០០០ ដុល្លារអាមេរិក។

មូលដ្ឋានវិភាគ បរិក្ខារកើនឡើងចំនួន $ ២២.០០០ សាច់ប្រាក់ថយចុះចំនួន $ ២២.០០០

## ការវិភាគសមីការគណនេយ្យ

ទ្រព្យសកម្ម = បំណុល + មូលធនទ្រព្យម្ចាស់

| សាច់ប្រាក់ | គណនីត្រូវទារ | អគារ | បរិក្ខារ | | គណនីត្រូវសង | | ដើមទុនលោកបូរី |
|---|---|---|---|---|---|---|---|
| +៩០០.០០០ | | +១០០.០០០ | | | | | +១.០០០.០០០ |
| | +២៨០.០០០ | | | | | | +២៨០.០០០ |
| +១៥០.០០០ | -១៥០.០០០ | | | | | | |
| -៥០.០០០ | | | | | | | -៥០.០០០ |
| -២២.០០០ | | | +១០.០០០<br>+៨.០០០<br>+៤.០០០ | | | | |

## ការវិភាគឥណពន្ធ-ឥណទាន

បរិក្ខារ

| ឥណពន្ធ | ឥណទាន |
|---|---|
| $ ១០.០០០ | |
| $ ៨.០០០ | |
| $ ៤.០០០ | |

សាច់ប្រាក់

| ឥណពន្ធ | ឥណទាន |
|---|---|
| | $ ៣០០ |

ការចុះទិន្នានុប្បវត្តិ

| | | | | |
|---|---|---|---|---|
| ១ | បរិក្ខារ | ១០៤ | $ ២២.០០០ | |
| កក្កដា | សាច់ប្រាក់ | ១០១ | | $ ២២.០០០ |
| | (ទិញបរិក្ខារ) | | | |

## ការចុះសក្ខីបត្រចុះបញ្ជី

| បរិក្ខារ | ១០៤ |
|---|---|
| ១ កក្កដា<br>$ ២២.០០០ | |

| សាច់ប្រាក់ | ១០១ |
|---|---|
| | ១ កក្កដា<br>$ ២២.០០០ |

ព្រឹត្តិការណ៍ ៦. នៅថ្ងៃទី១ ខែសីហាក្រុមហ៊ុនបានបង់ប្រាក់ក្រុមហ៊ុនផ្សាយពាណិជ្ជកម្ម ចំនួន៣.០០០ ដុល្លារអាមេរិក

មូលដ្ឋាននៃការវិភាគ ចំណាយកើនឡើងចំនួន $ ៣.០០០ ហើយសាច់ប្រាក់ថយចុះចំនួន $ ៣.០០០

## ការវិភាគសមីការគណនេយ្យ

| ទ្រព្យសកម្ម | | | | = | បំណុល | + | មូលធនទ្រព្យម្ចាស់ |
|---|---|---|---|---|---|---|---|
| សាច់ប្រាក់ | គណនីត្រូវទារ | អគារ | បរិក្ខារ | | គណនីត្រូវសង | | ដើមទុនលោកប៊ូរី |
| +៩០០.០០០ | | +១០០.០០០ | | | | | +១.០០០.០០០ |
| | +២៨០.០០០ | | | | | | +២៨០.០០០ |
| +១៥០.០០០ | -១៥០.០០០ | | | | | | |
| -៥០.០០០ | | | | | | | -៥០.០០០ |
| -២២.០០០ | | | +១០.០០០<br>+៨.០០០<br>+៤.០០០ | | | | |
| -៣.០០០ | | | | | | | -៣.០០០ |

## ការវិភាគឥណពន្ធ-ឥណទាន

ចំណាយផ្សាយពាណិជ្ជកម្ម

| ឥណពន្ធ | ឥណទាន |
|---|---|
| $ ៣.០០០ | |

សាច់ប្រាក់

| ឥណពន្ធ | ឥណទាន |
|---|---|
| | $ ៣.០០០ |

ការចុះទិន្នានុប្បវត្តិ

| | | | | |
|---|---|---|---|---|
| ១ សីហា | ចំណាយផ្សាយពាណិជ្ជកម្ម | ៥០២ | $ ៣.០០០ | |
| | សាច់ប្រាក់ | ១០១ | | $ ៣.០០០ |
| | (បង់ឱ្យក្រុមហ៊ុនផ្សាយពាណិជ្ជកម្ម) | | | |

## ការចុះសក្ខីបត្រចុះបញ្ជី

ចំណាយផ្សាយពាណិជ្ជកម្ម ៥០២

| | |
|---|---|
| ១ សីហា $ ៣.០០០ | |

សាច់ប្រាក់ ១០១

| | |
|---|---|
| | ២០ ធ្នូ $ ៣.០០០ |

ព្រឹត្តិការណ៍៧.

នៅថ្ងៃទី១០ ខែកញ្ញា ក្រុមហ៊ុនបានទទួលការសាងសង់មួយដែលមានតម្លៃ ១៦០.០០០ដុល្លារអាមេរិកមូលដ្ឋាននៃការវិភាគ ចំណូលកើនឡើងចំនួន $ ១៦០.០០០ គណនីត្រូវទារកើនឡើងចំនួន $ ៨០០ ដូចគ្នាការវិភាគសមីការគណនេយ្យ

| ទ្រព្យសកម្ម | | | | = | បំណុល | + | មូលធនទ្រព្យម្ចាស់ |
|---|---|---|---|---|---|---|---|
| សាច់ប្រាក់ | គណនីត្រូវទារ | អគារ | បរិក្ខារ | | គណនីត្រូវសង | | ដើមទុនលោកបូរី |
| +៩០០.០០០ | | +១០០.០០០ | | | | | +១.០០០.០០០ |
| | +២៨០.០០០ | | | | | | +២៨០.០០០ |
| +១៥០.០០០ | -១៥០.០០០ | | | | | | |
| -៥០.០០០ | | | | | | | -៥០.០០០ |
| -២២.០០០ | | | +១០.០០០<br>+៨.០០០<br>+៤.០០០ | | | | |
| -៣.០០០ | | | | | | | -៣.០០០ |
| | +១៦០០.០០០ | | | | | | +១៦០.០០០ |

## ការវិភាគឥណពន្ធ-ឥណទាន

គណនីត្រូវទារ

| ឥណពន្ធ | ឥណទាន |
|---|---|
| $ ១៦០.០០០ | |

ចំណូល

| ឥណពន្ធ | ឥណទាន |
|---|---|
| | $ ១៦០.០០០ |

ការចុះទិន្នានុប្បវត្តិ

| | | | | |
|---|---|---|---|---|
| ១០ កញ្ញា | គណនីត្រូវទារ | ១០២ | $ ១៦០.០០០ | |
| | ចំណូល<br>(ចំណូលពីសេវាកម្មសាងសង់) | ៤០១ | | $ ១៦០.០០០ |

## ការចុះសក្ខីបត្រចុះបញ្ជី

| គណនីត្រូវទារ ១០២ | |
|---|---|
| ១០ កញ្ញា | |
| $ ១៦០.០០០ | |

| ចំណូល ៤០១ | |
|---|---|
| | ១០ កញ្ញា |
| | $ ១៦០.០០០ |

ព្រឹត្តិការណ៍ ៨. នៅថ្ងៃទី១៥ ខែកញ្ញា ក្រុមហ៊ុនបានទទួលសាច់ប្រាក់ចំនួន ១៣០.០០០ ដុល្លារទៀត

**មូលដ្ឋាននៃការវិភាគ** សាច់ប្រាក់កើនឡើងចំនួន $ ១៣០.០០០ គណនីត្រូវទារថយចុះចំនួន $ ១៣០.០០០

## ការវិភាគសមីការគណនេយ្យ

| ទ្រព្យសកម្ម | | | | = | បំណុល | + | មូលធនទ្រព្យម្ចាស់ |
|---|---|---|---|---|---|---|---|
| សាច់ប្រាក់ | គណនីត្រូវទារ | អគារ | បរិក្ខារ | | គណនីត្រូវសង | | ដើមទុនលោកបូរី |
| +៩០០.០០០ | | +១០០.០០០ | | | | | +១.០០០.០០០ |
| | +២៨០.០០០ | | | | | | +២៨០.០០០ |
| +១៥០.០០០ | -១៥០.០០០ | | | | | | |
| -៥០.០០០ | | | | | | | -៥០.០០០ |
| -២២.០០០ | | | +១០.០០០<br>+៨.០០០<br>+៤.០០០ | | | | |
| -៣.០០០ | | | | | | | -៣.០០០ |
| | +១៦០០.០០០ | | | | | | +១៦០.០០០ |
| +១៣០.០០០ | -១៣០.០០០ | | | | | | |

**ការវិភាគឥណពន្ធ-ឥណទាន**

សាច់ប្រាក់

| ឥណពន្ធ | ឥណទាន |
|---|---|
| $ ១៣០.០០០ | |

គណនីត្រូវទារ

| ឥណពន្ធ | ឥណទាន |
|---|---|
| | $ ១៣០.០០០ |

ការចុះទិន្នានុប្បវត្តិ

| | | | | |
|---|---|---|---|---|
| ១៥ កញ្ញា | សាច់ប្រាក់ | ១០១ | $ ១៣០.០០០ | |
| | គណនីត្រូវទារ (អតិថិជនសងប្រាក់) | ១០២ | | $ ១៣០.០០០ |

**ការចុះសក្ខីបត្រចុះបញ្ជី**

សាច់ប្រាក់ ១០១

| | |
|---|---|
| ១៥ កញ្ញា $ ១៣០.០០០ | |

គណនីត្រូវទារ ១០២

| | |
|---|---|
| | ១៥ កញ្ញា $ ១៣០.០០០ |

ព្រឹត្តិការណ៍ ៩. នៅថ្ងៃទី៣០ ខែធ្នូ ក្រុមហ៊ុនបានបើកប្រាក់ឈ្នួលឱ្យកម្មករចំនួន ៥០.០០០ ដុល្លារអាមេរិកមូលដ្ឋាននៃការវិភាគ ចំណាយកើនឡើងចំនួន $ ៥០.០០០ សាច់ប្រាក់ថយចុះចំនួន $ ៥០.០០០

## ការវិភាគសមីការគណនេយ្យ

| ទ្រព្យសកម្ម | | | | = | បំណុល | + | មូលធនទ្រព្យម្ចាស់ |
|---|---|---|---|---|---|---|---|
| សាច់ប្រាក់ | គណនីត្រូវទារ | អគារ | បរិក្ខារ | | គណនីត្រូវសង | | ដើមទុនលោកបូរី |
| +៩00.000 | | +១00.000 | | | | | +១.000.000 |
| | +២៨0.000 | | | | | | +២៨0.000 |
| +១៥0.000 | -១៥0.000 | | | | | | |
| -៥0.000 | | | | | | | -៥0.000 |
| -២២.000 | | | +១0.000<br>+៨.000<br>+៤.000 | | | | |
| -៣.000 | | | | | | | -៣.000 |
| | +១៦00.000 | | | | | | +១៦0.000 |
| +១៣0.000 | -១៣0.000 | | | | | | |
| -៥0.000 | | | | | | | -៥0.000 |

## ការវិភាគឥណពន្ធ-ឥណទាន

សាច់ប្រាក់

| ឥណពន្ធ | ឥណទាន |
|---|---|
| $ ៥0.000 | |

ចំណាយប្រាក់ឈ្នួល

| ឥណពន្ធ | ឥណទាន |
|---|---|
| | $ ៥0.000 |

ការចុះទិន្នានុប្បវត្តិ

| | | | | |
|---|---|---|---|---|
| ៣០ ធ្នូ | ចំណាយប្រាក់ឈ្នួល<br>សាច់ប្រាក់<br>(បើកប្រាក់ឈ្នួលឱ្យកម្មករ) | ១០១<br>៥០១ | $ ៥០.០០០ | <br>$ ៥០.០០០ |

ការចុះសក្ខីបត្រចុះបញ្ជី

| ចំណាយប្រាក់ឈ្នួល ៥០១ | |
|---|---|
| ៣០ ធ្នូ $ ៥០.០០០ | |

| សាច់ប្រាក់ ១០១ | |
|---|---|
| | ៣០ ធ្នូ $ ៥០.០០០ |

ព្រឹត្តិការណ៍ ១០.

នៅថ្ងៃទី៣១ ខែធ្នូ ក្រុមហ៊ុនបានបង់ថ្លៃទឹកភ្លើងចំនួន៥.០០០ ដុល្លារអាមេរិក។មូលដ្ឋាននៃការវិភាគ ចំណាយកើនឡើងចំនួន $៥.០០០ សាច់ប្រាក់ថយចុះចំនួន $៥.០០០

## ការវិភាគសមីការគណនេយ្យ

**ទ្រព្យសកម្ម = បំណុល + មូលធនទ្រព្យម្ចាស់**

| សាច់ប្រាក់ | គណនីត្រូវទារ | អគារ | បរិក្ខារ | | គណនីត្រូវសង | | ដើមទុនលោកបូរី |
|---|---|---|---|---|---|---|---|
| +៩០០.០០០ | | +១០០.០០០ | | | | | +១.០០០.០០០ |
| | +២៨០.០០០ | | | | | | +២៨០.០០០ |
| +១៥០.០០០ | -១៥០.០០០ | | | | | | |
| -៥០.០០០ | | | | | | | -៥០.០០០ |
| -២២.០០០ | | | +១០.០០០<br>+៨.០០០<br>+៤.០០០ | | | | |
| -៣.០០០ | | | | | | | -៣.០០០ |
| | +១៦០០.០០០ | | | | | | +១៦០.០០០ |
| +១៣០.០០០ | -១៣០.០០០ | | | | | | |
| -៥០.០០០ | | | | | | | -៥០.០០០ |
| -៥.០០០ | | | | | | | -៥.០០០ |

## ការចុះទិន្នានុប្បវត្តិ

| | | | | |
|---|---|---|---|---|
| ៣១ ធ្នូ | ចំណាយទឹកភ្លើង | ១០៣ | $ ៥០.០០០ | |
| | សាច់ប្រាក់ | ៥០១ | | $ ៥០.០០០ |
| | (ចំណាយទឹកភ្លើងប្រចាំឆ្នាំ) | | | |

## ការចុះសក្ខីបត្រចុះបញ្ជី

ចំណាយទឹកភ្លើង ៥០៣

| | |
|---|---|
| ៣១ ធ្នូ<br>$ ៥.០០០ | |

សាច់ប្រាក់ ១០១

| | |
|---|---|
| | ៣១ ធ្នូ<br>$ ៥.០០០ |

ករណី(ខ)

១-ការកត់ត្រាសមីការគណនេយ្យសង្ខេប (Equation Account Summary)

| ទ្រព្យសកម្ម | | | | = | បំណុល | + | មូលធនទ្រព្យម្ចាស់ |
|---|---|---|---|---|---|---|---|
| សាច់ប្រាក់ | គណនីត្រូវទារ | អគារ | បរិក្ខារ | | គណនីត្រូវសង | | ដើមទុនលោកបូរី |
| +៩០០.០០០ | | +១០០.០០០ | | | | | +១.០០០.០០០ |
| | +២៨០.០០០ | | | | | | +២៨០.០០០ |
| +១៥០.០០០ | -១៥០.០០០ | | | | | | |
| -៥០.០០០ | | | | | | | -៥០.០០០ |
| -២២.០០០ | | | +១០.០០០<br>+៨.០០០<br>+៤.០០០ | | | | |
| -៣.០០០ | | | | | | | -៣.០០០ |
| | +១៦០.០០០ | | | | | | +១៦០.០០០ |
| +១៣០.០០០ | -១៣០.០០០ | | | | | | |
| -៥០.០០០ | | | | | | | -៥០.០០០ |
| -៥.០០០ | | | | | | | -៥.០០០ |
| ១.០៥០.០០០ | ១៦០.០០០ | ១០០.០០០ | ២២.០០០ | = | | | ១.៣៣២.០០០ |

២-ការកត់ត្រាទិន្នានុប្បវត្តិទូទៅ(General Journal)

| ទិន្នានុប្បវត្តិទូទៅ | | | ទំព័រ ១ |
|---|---|---|---|
| ថ្ងៃ ខែ | បរិយាយ | ឥណពន្ធ | ឥណទាន |
| ១ មករា | សាច់ប្រាក់ | $ ៩០០.០០០ | |
| | អគារ | $ ១០០.០០០ | |
| | មូលធនទ្រព្យម្ចាស់ | | $ ១.០០០.០០០ |
| | (ដើមទុនបង្កើតក្រុមហ៊ុន) | | |
| ១៩ កុម្ភៈ | គណនីត្រូវទារ | $ ២៨០.០០០ | |
| | ចំណូល | | $ ២៨០.០០០ |
| | (ចំណូលពីសេវាសាងសង់) | | |
| ៨ ឧសភា | សាច់ប្រាក់ | $ ១៥០.០០០ | |
| | គណនីត្រូវទារ | | $ ១៥០.០០០ |
| | (អតិថិជនសងប្រាក់) | | |
| ១៦មិថុនា | ចំណាយប្រាក់ឈ្នួល | $ ៥០.០០០ | |
| | សាច់ប្រាក់ | | $ ៥០.០០០ |
| | (បើកប្រាក់ឈ្នួលឱ្យកម្មករ) | | |
| ១ កក្កដា | បរិក្ខារ | $ ២២.០០០ | |
| | សាច់ប្រាក់ | | $ ២២.០០០ |
| | (ទិញបរិក្ខារ) | | |
| ១ សីហា | ចំណាយផ្សាយពាណិជ្ជកម្ម | $ ៣.០០០ | |
| | សាច់ប្រាក់ | | $ ៣.០០០ |
| | (បង់ឱ្យក្រុមហ៊ុនផ្សាយពាណិជ្ជកម្ម) | | |
| ១០ កញ្ញា | គណនីត្រូវទារ | $ ១៦០.០០០ | |
| | ចំណូល | | $ ១៦០.០០០ |
| | (ចំណូលពីសេវាកម្មសាងសង់) | | |
| ១៥ កញ្ញា | សាច់ប្រាក់ | $ ១៣០.០០០ | |
| | គណនីត្រូវទារ | | $ ១៣០.០០០ |

| | | | |
|---|---|---|---|
| | (អតិថិជនសងប្រាក់) | | |
| ៣០ ធ្នូ | ចំណាយប្រាក់ឈ្នួល<br>សាច់ប្រាក់<br>(បើកប្រាក់ឈ្នួលឱ្យកម្មករ) | $ ៥០.០០០ | <br>$ ៥០.០០០ |
| ៣១ ធ្នូ | ចំណាយទឹកភ្លើង<br>សាច់ប្រាក់<br>( ចំណាយទឹកភ្លើងប្រចាំឆ្នាំ ) | $ ៥.០០០ | <br>$ ៥.០០០ |

## ៣-ការកត់ត្រាសៀវភៅធំទូទៅ( General ledger )

| សាច់ប្រាក់ | | | | | គណនី: ១០១ |
|---|---|---|---|---|---|
| ថ្ងៃខែ | បរិយាយ | យោង | ឥណពន្ធ | ឥណទាន | សមតុល្យ |
| | សមតុល្យដើមគ្រា | | | | $ 0 |
| ១ មករា | ដើមទុនបង្កើតក្រុមហ៊ុន | ទ១ | $ ៩០០.០០០ | | $ ៩០០.០០០ |
| ៨ ឧសភា | អតិថិជនសងប្រាក់ | ទ១ | $ ១៥០.០០០ | | $ ១.០៥០.០០០ |
| ១៦ មិថុនា | បើកប្រាក់ឈ្នួលឱ្យកម្មករ | ទ១ | | $ ៥០.០០០ | $ ១.០០០.០០០ |
| ១ កក្កដា | ទិញបរិក្ខារ | ទ១ | | $ ២២.០០០ | $ ៩៧៨.០០០ |
| ១ សីហា | បង់ឱ្យការផ្សាយពាណិជ្ជកម្ម | ទ១ | | $ ៣.០០០ | $ ៩៧៥.០០០ |
| ១៥ កញ្ញា | អតិថិជនសងប្រាក់ | ទ១ | $ ១៣០.០០០ | | $ ១.១០៥.០០០ |
| ៣០ ធ្នូ | បើកប្រាក់ឈ្នួលឱ្យកម្មករ | ទ១ | | $ ៥០.០០០ | $ ១.០៥៥.០០០ |
| ៣១ ធ្នូ | ចំណាយទឹកភ្លើងប្រចាំឆ្នាំ | ទ១ | | $ ៥.០០០ | $ ១.០៥០.០០០ |

| គណនីត្រូវទារ | | | | | គណនី: ១០២ |
|---|---|---|---|---|---|
| ថ្ងៃខែ | បរិយាយ | យោង | ឥណពន្ធ | ឥណទាន | សមតុល្យ |
| | សមតុល្យដើមគ្រា | | | | $ 0 |
| ១៩ កុម្ភៈ | ចំណូលពីសេវាសាងសង់ | ទ១ | $ ២៨០.០០០ | | $ ២៨០.០០០ |
| ៨ ឧសភា | អតិថិជនសងប្រាក់ | ទ១ | | $ ១៥០.០០០ | $ ១៣០.០០០ |
| ១០ កញ្ញា | ចំណូលពីសេវាកម្មសាងសង់ | ទ១ | $ ១៦០.០០០ | | $ ២៩០.០០០ |
| ១៥ កញ្ញា | អតិថិជនសងប្រាក់ | | | $ ១៣០.០០០ | $ ១៦០.០០០ |

| អគារ | | | | | គណនី: ១០៣ |
|---|---|---|---|---|---|
| ថ្ងៃខែ | បរិយាយ | យោង | ឥណពន្ធ | ឥណទាន | សមតុល្យ |
| | សមតុល្យដើមគ្រា | | | | $ 0 |
| ១ មករា | ដើមទុនបង្កើតក្រុមហ៊ុន | ទ១ | $ ១០០.000 | | $ ១០០.000 |

| បរិក្ខារ | | | | | គណនី: ១០៤ |
|---|---|---|---|---|---|
| ថ្ងៃខែ | បរិយាយ | យោង | ឥណពន្ធ | ឥណទាន | សមតុល្យ |
| | សមតុល្យដើមគ្រា | | | | $ 0 |
| ១ កក្កដា | ទិញបរិក្ខារ | ទ១ | $ ២២.000 | | $ ២២.000 |

| គណនីត្រូវសង | | | | | គណនី: ២០១ |
|---|---|---|---|---|---|
| ថ្ងៃខែ | បរិយាយ | យោង | ឥណពន្ធ | ឥណទាន | សមតុល្យ |
| | សមតុល្យដើមគ្រា | | | | $ 0 |
| | | | | | $ 0 |

| មូលធនទ្រព្យម្ចាស់ | | | | | គណនី: ៣០១ |
|---|---|---|---|---|---|
| ថ្ងៃខែ | បរិយាយ | យោង | ឥណពន្ធ | ឥណទាន | សមតុល្យ |
| | សមតុល្យដើមគ្រា | | | | $ 0 |
| ១ មករា | ដើមទុនបង្កើតក្រុមហ៊ុន | ទ១ | | $ ១.000.000 | $ ១.000.000 |
| ១៩ កុម្ភៈ | ចំណូលពីសេវាសាងសង់ | ទ១ | | $ ២៨0.000 | $ ១.២៨0.000 |
| ១៦មិថុនា | បើកប្រាក់ឈ្នួលឱ្យកម្មករ | ទ១ | $ ៥0.000 | | $ ១.២៣0.000 |
| ១ សីហា | បង់ឱ្យការផ្សាយពាណិជ្ជកម្ម | ទ១ | $ ៣.000 | | $ ១.២២៧.000 |
| ១០ កញ្ញា | ចំណូលសេវាកម្មសាងសង់ | ទ១ | | $ ១៦0.000 | $ ១.៣៨៧.000 |
| ៣0 ធ្នូ | បើកប្រាក់ឈ្នួលឱ្យកម្មករ | ទ១ | $ ៥0.000 | | $ ១.៣៣៧.000 |
| ៣១ ធ្នូ | ចំណាយទឹកភ្លើងប្រចាំឆ្នាំ | ទ១ | $ ៥.000 | | $ ១.៣៣២.000 |

| ចំណូល | | | | | គណនី: ៤០១ |
|---|---|---|---|---|---|
| ថ្ងៃខែ | បរិយាយ | យោង | ឥណពន្ធ | ឥណទាន | សមតុល្យ |
| ១៩ កុម្ភៈ | ចំណូលពីសេវាសាងសង់ | ទ១ | | $ ២៨០.០០០ | $ ២៨០.០០០ |
| ១០ កញ្ញា | ចំណូលពីសេវាកម្មសាងសង់ | ទ១ | | $ ១៦០.០០០ | $ ៤៤០.០០០ |

| ចំណាយប្រាក់ឈ្នួល | | | | | គណនី: ៥០១ |
|---|---|---|---|---|---|
| ថ្ងៃខែ | បរិយាយ | យោង | ឥណពន្ធ | ឥណទាន | សមតុល្យ |
| ១៦ មិថុនា | បើកប្រាក់ឈ្នួលឱ្យកម្មករ | ទ១ | $ ៥០.០០០ | | $ ៥០.០០០ |
| ៣០ ធ្នូ | បើកប្រាក់ឈ្នួលឱ្យកម្មករ | ទ១ | $ ៥០.០០០ | | $ ១០០.០០០ |

| ចំណាយផ្សាយពាណិជ្ជកម្ម | | | | | គណនី: ៥០២ |
|---|---|---|---|---|---|
| ថ្ងៃខែ | បរិយាយ | យោង | ឥណពន្ធ | ឥណទាន | សមតុល្យ |
| ១ សីហា | បង់ឱ្យការផ្សាយពាណិជ្ជកម្ម | ទ១ | $ ៣.០០០ | | $ ៣.០០០ |

| ចំណាយទឹកភ្លើង | | | | | គណនី: ៥០៣ |
|---|---|---|---|---|---|
| ថ្ងៃខែ | បរិយាយ | យោង | ឥណពន្ធ | ឥណទាន | សមតុល្យ |
| ៣១ ធ្នូ | ចំណាយទឹកភ្លើងប្រចាំឆ្នាំ | ទ១ | $ ៥.០០០ | | $ ៥.០០០ |

**៤-តារាងបញ្ជីទ្រព្យសកម្ម និងការគណនារំលស់**

| ទ្រព្យសកម្ម | អាយុកាលប្រើប្រាស់ | ភាគរយ |
|---|---|---|
| អគារ | ២០ឆ្នាំ | ៥%ក្នុងមួយឆ្នាំ |
| កុំព្យូទ័រ | ២ឆ្នាំ | ៥០%ក្នុងមួយឆ្នាំ |
| យានយន្ត | ៤ឆ្នាំ | ២៥%ក្នុងមួយឆ្នាំ |
| គ្រឿងសង្ហារិម | ៥ឆ្នាំ | ២០%ក្នុងមួយឆ្នាំ |

| ថ្ងៃខែឆ្នាំទិញ | បរិយាយ | ថ្លៃដើម | ភាគរយ | ខែ | ចំណាយរំលស់ ៣១ ធ្នូ ២០២២ | តម្លៃបញ្ជីសុទ្ធ |
|---|---|---|---|---|---|---|
| ១ មករា ២២ | អគារការិយាល័យ | ១០០.០០០ | ៥% | ១២ | ៥.០០០ | ៩៥.០០០ |
| ១ កក្កដា ២២ | កុំព្យូទ័រ | ៤.០០០ | ៥០% | ៦ | ១.០០០ | ៣.០០០ |
| ១ កក្កដា ២២ | យានយន្ត | ១០.០០០ | ២៥% | ៦ | ១.២៥០ | ៨.៧៥០ |

| | | | | | | |
|---|---|---|---|---|---|---|
| ១ កក្កដា ២២ | គ្រឿងសង្ហារិម | ៨.០០០ | ២០% | ៦ | ៨០០ | ៧.២០០ |
| | | | | សរុប | ៨.០៥០ | ១១៣.៩៥០ |

## ក ) សន្លឹកកិច្ចការ

**អង្គរ ខន់ស្រ្កាក់សិន**
**សន្លឹកកិច្ចការ**
**ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២**

| | តុល្យការសាកល្បង | | ការកែតម្រូវ | | ក្រោយកែតម្រូវ | |
|---|---|---|---|---|---|---|
| គណនី | ឥណពន្ធ | ឥណទាន | ឥណពន្ធ | ឥណទាន | ឥណពន្ធ | ឥណទាន |
| សាច់ប្រាក់ | $ ១.០៥០.០០០ | | | | $១.០៥០.០០០ | |
| គណនីត្រូវទារ | $ ១៦០.០០០ | | | | $ ១៦០.០០០ | |
| អគារ | $ ១០០.០០០ | | | $ ៥.០០០ | $ ៩៥.០០០ | |
| បរិក្ខារ | $ ២២.០០០ | | | $ ៣.០៥០ | $ ១៨.៩៥០ | |
| គណនីត្រូវសង | | $ 0 | | | | $ 0 |
| មូលធនទ្រព្យម្ចាស់ | | $១.០០០.០០០ | | | | $១.០០០.០០០ |
| ចំណូល | | $៤៤០.០០០ | | | | $៤៤០.០០០ |
| ចំណាយប្រាក់ឈ្នួល | $ ១០០.០០០ | | | | $ ១០០.០០០ | |
| ផ្សាយពាណិជ្ជកម្ម | $ ៣.០០០ | | | | $ ៣.០០០ | |
| ចំណាយទឹកភ្លើង | $ ៥.០០០ | | | | $ ៥.០០០ | |
| ចំណាយរំលស់ | | | $ ៨.០៥០ | | $ ៨.០៥០ | |
| | ១.៤៤០.០០០ | ១.៤៤០.០០០ | ៨.០៥០ | ៨.០៥០ | ១.៤៤០.០០០ | ១.៤៤០.០០០ |

## ០ ) -ទិន្នានុប្បវត្តិបិទបញ្ជី

| ទិន្នានុប្បវត្តិបិទបញ្ជី | | | |
|---|---|---|---|
| ថ្ងៃ ខែ | បរិយាយ | ឥណពន្ធ | ឥណទាន |
| ៣១ ខែធ្នូ | ចំណូល | $ ៤៤០.០០០ | |
| | គណនីកម្រៃសង្ខេប | | $ ៤៤០.០០០ |
| | (បិទគណនីចំណូល) | | |
| ៣១ ខែធ្នូ | គណនីកម្រៃសង្ខេប | $ ១១៦.០៥០ | |
| | ចំណាយប្រាក់ឈ្នួល | | $ ១០០.០០០ |
| | ចំណាយផ្សាយពាណិជ្ជកម្ម | | $ ៣.០០០ |
| | ចំណាយទឹកភ្លើង | | $ ៥.០០០ |
| | ចំណាយរំលស់ | | $ ៨.០៥០ |
| | (បិទគណនីចំណាយ និងថ្លៃដើម) | | |
| ៣១ ខែធ្នូ | គណនីកម្រៃសង្ខេប | $ ៣២៣.៩៥០ | |
| | ប្រាក់ចំណេញរក្សាទុក | | $ ៣២៣.៩៥០ |
| | (បិទគណនីចំណេញសុទ្ធទៅប្រាក់ចំណេញរក្សាទុក) | | |
| ៣១ ខែធ្នូ | ប្រាក់ចំណេញរក្សាទុក | $ ០ | |
| | ការដកដើមទុន | | $ ០ |
| | (បិទការដកដើមទុនទៅមូលធន) | | |

p) **របាយការណ៍ហិរញ្ញវត្ថុ**

ក-របាយការណ៍លទ្ធផល

អង្គរ ខន់ស្រ្តាក់សិន<br>របាយការណ៍លទ្ធផល<br>៣១ ធ្នូ ២០២២

| | | |
|---|---|---|
| ចំណូល | | $៤៤០.០០០ |
| ចំណាយប្រតិបត្តិការ | | |
| ចំណាយប្រាក់ឈ្នួល | $ ១០០.០០០ | |
| ចំណាយផ្សាយពាណិជ្ជកម្ម | $ ៣.០០០ | |
| ចំណាយរំលស់ | $ ៨.០៥០ | |
| ចំណាយទឹកភ្លើង | $ ៥.០០០ | |
| ចំណាយប្រតិបត្តិការសរុប | | $១១៦.០៥០ |
| ប្រាក់ចំណេញសុទ្ធ | | $៣២៣.៩៥០ |

ខ-របាយការណ៍មូលធនទ្រព្យម្ចាស់

អង្គរ ខន់ស្រ្តាក់សិន

## របាយការណ៍មូលធនទ្រព្យម្ចាស់

## ៣១ ធ្នូ ២០២២

| | | |
|---|---|---|
| មូលធនម្ចាស់ភាគហ៊ុនវិនិយោគនៅដើមគ្រា ថ្ងៃទី១ មករា | | $ 0 |
| បូកបន្ថែម: | វិនិយោគ | $ ១.000.000 |
| | ប្រាក់ចំណេញសុទ្ធ | $៣២៣.៩៥០ |
| ដក ចេញ: | ការដកដើមទុន | ( $ 0 ) |
| មូលធនម្ចាស់ភាគហ៊ុនវិនិយោគនៅចុងគ្រា ថ្ងៃទី៣១ ធ្នូ | | $១.៣២៣.៩៥០ |

គ-តារាងតុល្យការ

អង្គរ ខន់ស្រ្តាក់សិន

តារាងតុល្យការ

៣១ ធ្នូ ២០២២

| I-ទ្រព្យសកម្ម | ចំនួនទឹកប្រាក់ | |
|---|---|---|
| 1. ទ្រព្យសកម្មចរន្ត | | |
| សាច់ប្រាក់ | $ ១.០៥០.០០០ | |
| គណនីត្រូវទារ | $ ១៦០.០០០ | |
| 2. ទ្រព្យសកម្មរយៈពេលវែង | | |
| អគារ | $ ១០០.០០០ | |
| បរិក្ខារ | $ ២២.០០០ | |
| រំលស់បង្គរ | ($ ៨.០៥០ ) | |
| សរុបទ្រព្យសកម្ម | | $១.៣២៣.៩៥០ |

| II-បំណុលនិងមូលធនទ្រព្យម្ចាស់ | ចំនួនទឹកប្រាក់ | |
|---|---|---|
| 1. បំណុល | | |
| គណនីត្រូវសង | $ 0 | |
| 2. មូលធនទ្រព្យម្ចាស់ | | |
| មូលធន | $ ១.៣២៣.៩៥០ | |
| សរុបបំណុល និងមូលធន | | $ ១៣២៣.៩៥០ |

ឃ–របាយការណ៍លំហូរសាច់ប្រាក់

អង្គរ ខន់ស្រ្តាក់សិន

របាយការណ៍លំហូរសាច់ប្រាក់

៣១ ធ្នូ ២០២២

ចំនួនទឹកប្រាក់

I-លំហូរសាច់ប្រាក់មកពីសកម្មភាពប្រតិបត្តិការ

| | | |
|---|---|---|
| – ប្រាក់ចំណេញសុទ្ធ | $ ៣២៣.៩៥០ | |
| – គណនីត្រូវទារកើនឡើង | ($១៦០.០០០) | |
| – ចំណាយរំលស់ | ៨.០៥០ | |
| សាច់ប្រាក់ពិតពីសកម្មភាពប្រតិបត្តិកា | | $១៧២.០០០ |
| II-លំហូរសាច់ប្រាក់មកពីសកម្មភាពវិនិយោគ | | |
| – ការទិញបរិក្ខារ | ($ ២២.០០០) | |
| – អគារការិយាល័យ | ($ ១០០.០០០) | |
| សាច់ប្រាក់មកពីសកម្មភាពវិនិយោគ | | ( $ ១២២.០០០) |
| III-លំហូរសាច់ប្រាក់មកពីសកម្មភាពហិរញ្ញវត្ថុ | | |
| – វិនិយោគដោយម្ចាស់ | $ ១.០០០.០០០ | |
| – ការដកដោយម្ចាស់ | ($ ០) | |
| សាច់ប្រាក់មកពីសកម្មភាពវិនិយោគហិរញ្ញវត្ថុ | | $ ១.០០០.០០០ |
| សមតុល្យសាច់ប្រាក់ដើមគ្រា | $ ០ | |
| សមតុល្យសាច់ប្រាក់ចុងគ្រា | | $ ១.០៥០.០០០ |

## III. -សេចក្តីសន្និដ្ឋាន

ទ្រព្យសកម្មរបស់សហគ្រាសនីមួយៗ មានទាំងទ្រព្យសកម្មរយៈពេលខ្លីនិងទ្រព្យសកម្មរយៈពេលវែង ដែលទ្រព្យសកម្មរយៈពេលវែងត្រូវបានគេធ្វើរំលស់។ ថ្លៃ

ដើមនៃទ្រព្យសកម្មរយៈពេលវែង ត្រូវបានកាត់រំលស់ហើយក្លាយជាតម្លៃក្នុងបញ្ជីសុទ្ធពីមួយឆ្នាំទៅមួយឆ្នាំ ដោយដករំលស់បង្គរ។ វិធីសាស្ត្ររំលស់ត្រូវបានគេធ្វើឡើងដោយវិធីសាស្ត្ររំលស់ថេរ វិធីសាស្ត្ររំលស់ថយជាលំដាប់ និងរំលស់តាមឯកតា។ ដាក់ស្តែងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ ក្រុមហ៊ុនអង្គរ ខន់ស្រ្តាក់សិន ដែលមានអគារការិយាល័យ ការទិញរថយន្ត ការទិញកុំព្យូទ័រ ការទិញគ្រឿងសង្ហារិម ហើយត្រូវបានធ្វើរំលស់តាមវិធីសាស្ត្ររំលស់ថេរ។ ទ្រព្យសកម្មរបស់ក្រុមហ៊ុន ក៏បង្ហាញពីភាពខ្លាំងផងដែរ នៅពេលដែលក្រុមហ៊ុនមានទ្រព្យសកម្មច្រើន ធៀបនឹងបំណុល។

## IV. ឯកសារយោង


1. Basic Accounting, by Long Savang and Hem Chanratanak, Asia Euro University, School of Business, Economics & Tourism 2008
2. **Financial Accounting, 4e Weygandt, Kieso, & Kimmel**, Prepared by Gregory K. Lowry Mercer University, Marianne Bradford, The University of Tennessee, **John Wiley & Sons, Inc.**
3. Financial Accounting, Seventh Edition, Prepared by Coby Hamon, University of California Santa Barbara.

4. Cambodian International Financial Reporting Standard, Ministry of Finance and Economics of Kingdom of Cambodia
5. Business Policy by Lecturer Dr. Keo Chea
6. Law on Taxation, dated 08 January 1997, Ministry of Finance and Economics of Kingdom of Cambodia
7. Prakas on Tax on Income, dated 29 January 2020, Ministry of Finance and Economics of Kingdom of Cambodia
8. The template provided by Lecturer Dr. Keo Chea